**BMI0087**

# សម្ភាសន៍ជាមួយឈ្មោះ ម៉ាន់ ជួន ភេទប្រុស អាយុ៥៨ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម«យោធា»

## រស់ភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

**ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ សោម ប៊ុនថន**

**០១:១៨:៣៦**

**៤៦ទំព័រ**

ប៊ុនថនៈ ជាដំបូងខ្ញុំសូមអនុញ្ញាតស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

ជួនៈ ខ្ញុំឈ្មោះម៉ាន់ ជួន។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយ?

ជួនៈ ខ្ញុំបច្ចុប្បន្នអាយុ៥៨ឆ្នាំហើយ។

ប៊ុនថនៈ ពូមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ជួនៈ ស្រុកកំណើតនៅភូមិផ្គាំ ឃុំផ្គាំ ស្រុកថ្មពួក ខេត្តបាត់ដំបង។

ប៊ុនថនៈ បាទ។

ជួនៈ ដល់បច្ចុប្បន្ន ភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

ប៊ុនថនៈ ដូរនៅឆ្នាំណាដែលពូ?

ជួនៈ ដូរកាលឆ្នាំប៉ុន្មានទេ គេបង្កើតស្រុកថ្មីវាដូចជា២០០៨។

ប៊ុនថនៈ បាទ។

ជួនៈ អេ!មិនមែនទេ ៩៨។

ប៊ុនថនៈ ចឹង៩៨ផ្លាស់ពីស្រុក?

ជួនៈ ពីស្រុកថ្មពួក។

ប៊ុនថនៈ ថ្មពួកមកស្វាយចេកវិញ កាលមុន។

ជួនៈ វាភ្លេចវានិយាយទៅ។

ប៊ុនថនៈ ចឹងលោកពូបានរៀនសូត្របានថ្នាក់ទីប៉ុន្មានដែលលោកពូ?

ជួនៈ កាលខ្ញុំរៀន រៀនបានថ្នាក់ទី៧ សម័យលន់ នល់ណាស់។

ប៊ុនថនៈ បាទ។

ជួនៈ ដល់រៀនទៅជួបប្រទះនិងភាពក្រីក្ររបស់ឪពុកម្តាយ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់សម័យលន់ នល់ទៅឪពុកខ្ញុំ សម័យនោះគេរើសទាហាន គេរើសទាហានកាលគេធ្វើរដ្ឋប្រហាជាមួយសម្តេចតានោះណា ។

ប៊ុនថនៈ បាទ ។

ជួនៈ លន់ នល់ធ្វើរដ្ឋប្រហាសម្តេចតាទៅឪពុកខ្ញុំធ្វើទាហាន គេដើររើសទាហានតាមភូមិយកទៅធ្វើទាហានហើយឪពុកខ្ញុំគាត់ទៅធ្វើទាហានគាត់ទៅរស់នៅក្នុងទីក្រុងភ្នំពេញ ។

ប៊ុនថនៈ បាទ ។

ជួនៈ ទៅនៅភ្នំពេញដល់គាត់មានវិបត្តិមានជំងឺខ្លួនគាត់ដែលធ្វើសង្គ្រាមនៅវ៉ៃនៅកំពង់ធំ តាំងក្រសាំងខេត្តកំពង់ធំ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់គាត់ចូលផ្ទះរោគគាត់ដែលគ្រាប់ផ្លោងខ្ទាំងមកបានធ្វើទុករោគប្រចាំកាយខ្លួនគាត់ដេកនៅពេទ្យរុស្សីគាត់ស្លាប់ទៅណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់គាត់ឈឺយ៉ាប់យកខ្ញុំទៅហើយបានគាត់ស្លាប់ កាលហ្នឹងគាត់យកខ្ញុំថែរក្សាគាត់នៅពេទ្យរុស្សីកាលឆ្នាំ៧២-៧៣ដែលកាលគេផ្តាច់ស្ពានជ្រោយចង្វារនេះ ។

ប៊ុនថនៈ បាទ ។

ជួនៈ កាលផ្តាច់ស្ពានជ្រោយចង្វារខ្ញុំនៅនោះឯង ខ្ញុំនៅហ្នឹងស៊ឹងមានជ័យ នៅវត្តស៊ឹងមានជ័យតែម្តង នៅលើម៉ុងចិនហ្នឹងឯង ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំស្គាល់អស់កន្លែងនោះឯង តាំងពីអាយុខ្ញុំ១៧-១៨ឆ្នាំនោះ ។

ប៊ុនថនៈ និយាយថាមុនឪពុកពូធ្វើទាហានលន់ នល់ជ្រើសរើសហ្នឹងគាត់ធ្វើអីដែលនៅក្នុងភូមិ?

ជួនៈ គាត់ធ្វើជាទាហាន គាត់បានពាក់អាសាជង់សែបដោយបីដាន់នោះណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដោយបីដាន់គាត់គ្រប់គ្រងទាហាននៅជាមួយលោកអ៊ុក ប៊ុនឈិន គាត់ពាក់សក្តិ៣ ប្រធានហៅកាម៉ុងដុងបាត់តាយ៉ុងនោះណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ គាត់ប្រចាំការនៅភ្នំពេញគាត់ចុះទៅបេសកម្មកំពង់ធំតាំងក្រសាំងវ៉ៃនៅកំពង់ធំ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់ឪពុកខ្ញុំស្លាប់រួចបានយូរដែលប្រហែលជាពីរបីខែ គេផ្លាស់ពួកអន្តភាពគាត់មកទៅនៅយើងសៀមរាប នៅសៀមរាបខ្ញុំក៏ទៅតាមគេនោះឯង ។

ប៊ុនថនៈ ទៅនៅជាមួយគេដែរ?

ជួនៈ បាទ!ទៅនៅយើងសៀមរាមនៅយើងស្ទឹខាងកើតសៀមរាបនៅដំដែក ។

ប៊ុនថនៈ បាទ ។

ជួនៈ ចុះពីដំដែកមកនេះ ចុះពីដំដែកមកនេះពីផ្សារអន្លង់ទៅរហូតទៅដល់អីដូនល្អក់ គា គតវ៉ៃគ្នាជាមួយខ្មែរក្រហមហ្នឹង នៅរហូតដល់ស្រុកគេតឹងតែងមែនទែនត្រឡប់មកវិញនៅជាមួយម្ដាយខ្ញុំទៅដល់ខ្មែរក្រហមចុះមកវ៉ៃភូមិផ្គាំទៅបែកទៅជម្លៀសខ្ញុំទៅនៅយើងស្នាច់ បើនិយាយសព្វថ្ងៃទឹកដីសៀមរាបនោះណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខាងនោះស៊ីងស្នាច់ ចារ ទម្រគាទ្រង់នេះ ដំរី ជ្រៃលុននេះ ។

ប៊ុនថនៈ នៅហ្នឹងគេហៅស្រុកអីវិញ?

ជួនៈ គេហៅស្រុកចង្កុកាល ។

ប៊ុនថនៈ ស្រុកចុងកាល?

ជួនៈ បាទ ។

ប៊ុនថនៈ សំរោងចុងកាលហ្នឹង?

ជួនៈ បាទ!សំរោងចុងកាល មានស្រុកចុងកាលអី ជ្រួយ ឃុំជ្រួយ ស្រុកស្រីស្នំ ស្រុកស្រីស្នំចេះតែភ្លេចដែរ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខេត្តសៀមរាប ដល់ត្រឡប់មកវិញពីនោះមកខ្ញុំ ខ្ញុំមកចូលកងទ័ពនៅនេះឯងមកចុះម៉ុំភូមិផ្គាំ ឃុំផ្គាំ ស្រុកថ្មពួកយើងនេះ ដល់នេះទៅគេចេះតែដឹកនាំខ្ញុំទៅរហូតវ៉ៃម៉ុត្រង់នេះបែកបាក់ ខ្ញុំចូលកងទ័ពគេឲ្យទៅនៅព្រៃមាន់នោះណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ព្រៃមាន់ទៅខំតស៊ូជាងគេដើម្បីលប់លាងកំហុសឪពុកធ្វើទាហាននេះឯង ។

ប៊ុនថនៈ ចឹងទៅជាមួយខាងខ្មែរក្រហម?

ជួនៈ បាទ! ទៅជាមួយខ្មែរក្រហម ទៅរហូតដល់គេទម្លាក់ទង់សពួកខ្ញុំក៏មិនទាន់ជឿបានចូលមកស្រុកថ្មពួក ៧៥ នោះណា ។

ប៊ុនថនៈ បាទ ។

ជួនៈ ចូលមកដល់ស្រុកថ្មលពួកគេឯករាជ្យហើយ ឯករាជ្យមកគេរៀបចំពួកខ្ញុំនេះចូលទៅនៅភូមិភាគ ។

ប៊ុនថនៈ បាទ ។

ជួនៈ ភូមិភាគឲ្យខ្ញុំទៅនៅប៉ោយប៉ែតស្រុកអូរជ្រៅ ។

ប៊ុនថនៈ ស្រុកអូរជ្រៅ?

ជួនៈ បាទ! ស្រុកអូរជ្រៅការពារព្រំដែន ឲ្យខ្ញុំទៅនៅស្រុកអូរជ្រៅហ្នឹងការងារមិនមានពេលទំនេរទេ ទៅនៅមែនខ្ញុំឆ្ងកាត់ទៅនៅហើយមិនមានពេលទំនេរដល់ព្រឹកឡើងយប់ឡើងគេយាមទាំងយប់ទាំងថ្ងៃ ដល់ការហូបចុកបាយលាយត្រកួន ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំធ្លាប់ហើយបាយលាយត្រកួនកាត់ទាំងវែងៗ អន្ករពីរបីកំប៉ុងចឹងដាំបាយលាយត្រកួនឲ្យហូប ចូលបដិវត្តហើយកាលនោះអាយុ១៩ហើយ ។

ប៊ុនថនៈ កាលហ្នឹងពូចូលនៅពេលណា?

ជួនៈ ចូលសម័យយើង៧៥ហើយនេះ ។

ប៊ុនថនៈ ៧៥ហើយបានចូល?

ជួនៈ បាទ! ៧៥ហើយ ៧៤ខ្ញុំចូលកងទ័ពពីសម័យ៧៤ ។

ប៊ុនថនៈ បាទ ។

ជួនៈ កាលនោះមិនទាន់ឯករាជ្យទេកាលនោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ចូលពី៧៤រហូត ។

ប៊ុនថនៈ កាលហ្នឹងឪពុកលោកពូស្លាប់ហើយនៅ?

ជួនៈ ឪពុកស្លាប់តាំងពីឆ្នាំ៧១នោះ ។

ប៊ុនថនៈ ៧១?

ជួនៈ បាទ! ៧១-៧២ចុងឆ្នាំ៧១ចូល៧២ ។

ប៊ុនថន៖ បាទ!ចឹងចង់សួរត្រឡប់ទៅក្រោយវិញ ចង់ដឹងថាឪពុកលោកពូកាលនៅក្នុងភូមិនេះគាត់ធ្វើអីដែរ?

ជួន៖ គាត់នៅរកស៊ីធម្មតាមុខរបរកសិករ ។

ប៊ុនថន៖ បាទ ។

ជួន៖ មិត្តភក្តិគាត់នាំដើរជំនួយដួញប្រែទិញជ្រូកទិញគ្រោះ ។

ប៊ុនថន៖ បាទ ។

ជួន៖ កាលដើមមិញមានតែទិញជ្រូកទេ ទិញជ្រូកយកទៅលក់ទិញស្រូវមានតែប៉ុណ្ណោះឯងទិញជ្រូកទិញស្រូវខ្ញុំដឹក ។

ប៊ុនថន៖ បាទ ។

ជួន៖ អាជីវកម្មរបស់ឪពុកខ្ញុំធ្វើស្រែទិញជ្រូកទិញស្រូវឲ្យពួកអ្នកមាននោះណាស់ ។

ប៊ុនថន៖ បាទ ។

ជួន៖ មិត្តភក្តិគាត់សុទ្ធតែអ្នកមានដូចអ្នកព្រះនេត្រព្រះគេទៅអាមេរិចទៅបារាំងអស់ហើយ ។

ប៊ុនថន៖ បាទ ។

ជួន៖ គេនៅរស់ទេ ឪពុកខ្ញុំស្លាប់ហើយ ។

ប៊ុនថន៖ ចឹងម្តាយ?

ជួន៖ ម្តាយខ្ញុំស្លាប់នៅសម័យបីឆ្នាំខ្ញុំមិនបានឃើញទេ សុំគេមកមើលអ្នកឯងមិនបាច់មកមើលទេអ្នកឯងមិនមែនពេទ្យទេ ។

ប៊ុនថន៖ គាត់ស្លាប់ដោយសារអី?

ជួន៖ គាត់ស្លាប់ដោយសារជំងឺគាត់រោគរបេង ម្តាយខ្ញុំស្លាប់ដោយសាររោគរបេង ។

ប៊ុនថន៖ ចឹងពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ជួន៖ បងប្អូនខ្ញុំទាំងអស់៧នាក់តែស្លាប់អស់សព្វថ្ងៃនៅតែ៥នាក់ទេ ។

ប៊ុនថន៖ បាទ!ចឹងពូកូនទីប៉ុន្មាន?

ជួន៖ ខ្ញុំកូនទី១ ។

ប៊ុនថន៖ ចឹងមានបានរៀនអី រៀនបានតែលោកពូមួយឬក៏?

ជួន៖ រៀនបានដូចគ្នាតែរៀនបានតិចៗ រៀនមិនបានដូចខ្ញុំទេប្អូនៗនោះ ។

ប៊ុនថន៖ បាទ ។

ជួន៖ គាត់រៀនបានតិចៗរៀនបានមួយចេះៗតិចៗ ។

ប៊ុនថន៖	ចឹងឪពុកលោកពូជាទាហានលន់ នល់ហ្នឹងឆ្នាំណាលោកពូ?

ជួន៖	គាត់ចូលតាំងពីដើមឆ្នាំ៧១មក រដ្ឋប្រហារភ្លាមទៅគេបង្កើតមក ។

ប៊ុនថន៖	បាទ ។

ជួន៖	គេបង្កើតកងទ័ពទូទាំងភូមិ គេអូសទាញគ្នាមានខ្សែនោះណាស់ ។

ប៊ុនថន៖	បាទ ។

ជួន៖	អានេះធ្វើនេះអានេះធ្វើនោះចឹងទៅសម័យហ្នឹងចុះឯង ។

ប៊ុនថន៖	បាទ!ចឹងលោកពូទៅជាមួយគាត់តែម្នាក់ទេឬក៏?

ជួន៖	ខ្ញុំទៅតែឯងប្អូនៗនៅនេះទាំងអស់ ។

ប៊ុនថន៖	នៅក្នុងភូមិ?

ជួន៖	បាទ!នៅតូចៗ ខ្ញុំកាលហ្នឹងនៅស្ទើរដែលអាយុ១៧ឆ្នាំ មានអីធំកំពង់តែឆោតនោះ ។

ប៊ុនថន៖	បាទ ។

ជួន៖	ខ្ញុំបានទៅភ្នំពេញខ្ញុំឈានបានទៅដល់កំបូលអីដែលហ្នឹង ទៅនៅសេអ៊ីកំបូលអីហាត់រៀនគេហ្នឹងឯង ។

ប៊ុនថន៖	ចឹងកាលហ្នឹងពីចូលនេះដែរ?

ជួន៖	ដល់ឪពុកខ្ញុំស្លាប់ទៅគេឲ្យខ្ញុំ ដូចនិយាយរឿងអីដូចជាផ្សំមិនទាន់ពេញសិទ្ធគេផ្សំណាស់ ។

ប៊ុនថន៖	បាទ ។

ជួន៖	ទៅនិងគេទៅគេទៅបំពេញ"អេរីទីស" ណាស់ ។

ប៊ុនថន៖	បាទ ។

ជួន៖	សើច...ទាហានអេរីទីសគេចែកលុយឲ្យយើងចាយហ្នឹងទៅ ។

ប៊ុនថន៖	បាទ ។

ជួន៖	គេហៅបំពេញ"អេរីទីស"គ្រប់វ័ណ្ណយើងមិនទាន់មានអាយុពេញទេ ។

ប៊ុនថន៖	ចូលហាត់បានយូរដែលពូ?

ជួន៖	ហាត់បីខែណា ខ្ញុំទៅនៅជាមួយអ្នកធំចុះមេគាត់ជាពួកម៉ាកឪពុកខ្ញុំណាស់ ។

ប៊ុនថន៖	បាទ ។

ជួន៖	ដែលហាត់អីណាដូចជានៅជុំជាមួយមេ នៅភ្នំពេញក៏ឡានទៅណាក៏ឡាន ទំនេរក៏ទៅហាត់និងគេទៅ ។

ប៊ុនថន៖	បាទ ។

ជួនៈ ដឹងថានៅជុំមេ ។

ប៊ុនថនៈ តែដែលបានមកផ្ទះលេងទេ?

ជួនៈ អត់ទេ កាលនោះដែលបានមក ដល់មក មកបណ្តោយម្តាយខ្ញុំជួបវិបត្តិរឿងថារកស៊ីកាល ហ្នឹងបងប្អូនច្រើន ។

ប៊ុនថនៈ បាទ ។

ជួនៈ បងប្អូនខ្ញុំ៦ទៅ៧នាក់នោះកូនច្រើនមានណាសម័យនោះដល់ខ្ញុំចេញទៅធ្វើកងទ័ពបែកបាក់ រហូតខ្ញុំមកជួបបងប្អូនខ្ញុំវិញនៅឆ្នាំ៧៩ មកដល់ឃើញផ្ទះមានទេ មកដល់ដេកតែមួយយប់ មានមាសមួយដំឡឹង មាសមួយដំឡឹងហ្នឹងមាសប្រពន្ធដើមទៀត ។

ប៊ុនថនៈ បាទ ។

ជួនៈ មកដល់សុខចិត្តយកមាសនិងទៅដូរអង្ករចិញ្ចឹមប្អូននៅនោះទិញសារ៉ុងបានទៅដូរស្រូវដល់ភូមិ បេង ពីណាមកដឹងថាចិញ្ចឹមប្អូនឲ្យប្អូនបានស៊ីឆ្អែតឈប់ឃ្លានឈប់អីបានខ្ញុំត្រឡប់ទៅប្រពន្ធខ្ញុំ វិញ ។

ប៊ុនថនៈ បាទ ។

ជួនៈ នៅពោធិសាត់នៅលាច ។

ប៊ុនថនៈ បាទ ។

ជួនៈ ទៅដល់ហ្នឹងខ្ញុំទិញស្អីៗយកទៅផ្ញើរប្រពន្ធខ្ញុំ ទៅដល់ស្ពានព្រំប្រទល់ពោធិសាត់ស្វាយដូចកែវ ណាស់ ។

ប៊ុនថនៈ បាទ

ជួនៈ ប៉ះគេឆែកយកឥវ៉ាន់ព្រំដែនគេយកអស់តាំងពីម៉ោងស្អីៗដែលយើងទិញទៅឥវ៉ាន់ល្អៗគេ យកអស់រលីង ។

ប៊ុនថនៈ បាទ ។

ជួនៈ ប្រាក់បាតប្រាក់អីគេមិនឲ្យយើងចាយទេសម័យនោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ថាយើងមកពីតំបន់ខ្មាំងសើច... ។

ប៊ុនថនៈ ចឹងកាលពូទៅភ្នំពេញទៅហាត់ហ្នឹងពូមានបានឡើងទៅវ៉ៃអីទេ?

ជួនៈ ខ្ញុំកាលនោះកំពង់ហាត់មិនបានឡើងវ៉ៃ ត្រឡប់មកពីនោះវិញហាត់ចប់បានមកខេត្តសៀម រាបបានវ៉ៃជាមួយពួកខ្មែរក្រហម ។

ប៊ុនថន៖ បាទ ។

ជួន៖ បាទ!វ៉ៃនៅវត្តល្អក់ គា គតវ៉ៃរាល់ថ្ងៃ ។

ប៊ុនថន៖ ចឹងពូនៅជាមួយពីណាវិញមេ?

ជួន៖ សក្តិ៣ អួន ឈិន បែបគាត់ស្លាប់ហើយប្រហែលគេស្លាប់អស់ហើយនៅម៉ាជុំនេះទាហាននេះនៅតើបងចំអីក្រុមប្រឹក្សាឃុំសុទ្ធតែទាហានជាមួយគាត់ហើយ ។

ប៊ុនថន៖ បាទ ។

ជួន៖ បងយឿតសុទ្ធតែជាទាហានម៉ាសេរីនោះហើយ ចាស់ៗស្លាប់អស់ហើយនៅតែក្មេងៗ ក្មេងៗម៉ាសេរីគាត់ស្លាប់អស់ច្រើនដែរ តែមិនដែលស្លាប់ដោយសារគ្រូវគ្រាប់ទេ ស្លាប់ដោយសារសម័យពីឆ្នាំនោះ ។

ប៊ុនថន៖ បាទ ។

ជួន៖ តែមិនដឹងជាស្លាប់និងអីទេ បើខ្ញុំមិនបាននៅនេះ ។

ប៊ុនថន៖ ចឹងវ៉ៃនៅសៀមរាបយូរទេ?

ជួន៖ ខ្ញុំនៅសៀមរាបជិត៣ខែហ្នឹង ។

ប៊ុនថន៖ ចឹងកាលវ៉ៃមានស្លាប់ច្រើនទេ កាលវ៉ៃ?

ជួន៖ អត់អីទេ ទាហានចុះពួកខ្មែរក្រហមដែលហ៊ានមកវ៉ៃដល់ទីតាំង ។

ប៊ុនថន៖ បាទ ។

ជួន៖ វាមកឆ្មក់មួយភ្លេចៗ ឆ្មក់គ្រាប់ផ្លោងចូលកន្លែងទីតាំងធំ ខ្ញុំនៅតែកន្លែងវរៈកន្លែងអ្នកធំកាំភ្លើងគ្រប់ធុន ។

ប៊ុនថន៖ បន្ទាយនៅម្តុំណា?

ជួន៖ បន្ទាយនៅម្តុំវត្តល្អក់ ពូកែណាស់វត្តល្អក់ ។

ប៊ុនថន៖ បាទ ។

ជួន៖ បន្ទាយវត្តល្អក់ហ្នឹងគ្រាប់ផ្លោងអត់មានវិហារបេះណាស់ អត់មានខ្មែរក្រហមផ្លោងចូលបានទេ ។

ប៊ុនថន៖ យ៉ាងម៉េចវិញ?

ជួន៖ មកពីមុខធ្លាក់មុខបើមកចំហៀងផ្ទុះបើមកពីមុខមិនដែលដល់ទេ ។

ប៊ុនថន៖ បាទ ។

ជួន៖ បើហួសមិនដែលបែកទេ វត្តល្អក់និងពូកែតែម្តងដឹងថាពូកែតែម្តងវត្តល្អក់ ។

ប៊ុនថន៖	នៅក្នុងភូមិឃុំអីដែលពូ?

ជួន៖	ខ្ញុំដឹងថាវត្តល្អក់តា តតនៅអត្រ្គនដឹងថាជុំដែកមិនដឹងភូមិអី ។

ប៊ុនថន៖	បាទ ។

ជួន៖	ទៅសួរថាវត្តល្អក់ៗដឹងហើយវត្តហ្នឹងដឹងថាពូកែខ្ញុំជឿជាក់តែម្តង ។

ប៊ុនថន៖	បាទ ។

ជួន៖	ខ្ញុំនៅក្នុងវិហារកាលវ៉ៃ វ៉ៃខ្ទាំងនៅក្នុងវិហារជាមួយប្រពន្ធតា ឈិននោះណាស់ ។

ប៊ុនថន៖	ចឹងពីបន្ទាប់ពីនៅហ្នឹងបីខែពូនៅណាទៀត?

ជួន៖	ខ្ញុំត្រឡប់មកផ្ទះវិញ មកផ្ទះវិញគេរំដោះសម័យ៧៩ខ្ញុំមកនៅនេះឈ្លបគេឲ្យយាម ។

ប៊ុនថន៖	បាទ ។

ជួន៖	ខ្ញុំយាមភូមិថ្ងៃខ្មែរក្រហមវ៉ៃខ្ញុំនៅប៉ុស្តិ៍ នៅអាប៉ុស្តិ៍ខាងលិចផ្ទះមេភូមិ មេភូមិដែលប្អូនឯង ឈប់ឡាននោះ ។

ប៊ុនថន៖	បាទ ។

ជួន៖	ខាងលិចនេះឯងហើយអ្នកដែលនៅជុំ ជុំគ្នាបង១ថ្ងៃខ្ញុំបីបួននាក់ខ្មែរក្រហមវ៉ៃស្រែកចាប់ពី អូរមកចាប់បាញ់ប្រាវៗខ្ញុំមានសាវិនធីណាយមួយដើម ។

ប៊ុនថន៖	បាទ ។

ជួន៖	ហើយអ៊ឹមម៉ាស៊ីមួយដើមសុទ្ធរត់នៅពេលនោះហើយយកអាសាវិនកប់ទុកនៅក្រោយផ្ទះខ្ញុំរួច ហើយដល់ពេលគេវ៉ៃបែករំដោះទៅខ្ញុំលាក់កាំភ្លើងអស់រលីងរកមិនឃើញទេ បានគេ ជម្លៀសយើងទៅចេះទៅ ទៅហើយកំសត់កម្របានទៅនោះរួមបានខ្ញុំនឹកឃើញថា ខ្លាចគេ ណាស់ ។

ប៊ុនថន៖	បាទ ។

ជួន៖	សុខចិត្តចូលកងទ័ព ។

ប៊ុនថន៖	បាទ ។

ជួន៖	ដល់ធ្វើកងទ័ពរហូតដល់ធ្វើកងទ័ពគេយកទៅនៅប៉ោយប៉ែត នៅកងទ័ពទៅនៅប៉ោយប៉ែត មានឈ្មោះគ្នាឯងឈ្មោះជួនដូចខ្ញុំចឹងឯង ។

ប៊ុនថន៖	បាទ ។

ជួន៖	ជួនបងចោតប្អូនចោតគេចោទនោះណា ។

ប៊ុនថន៖	បាទ ។

ជួនៈ	គេរាយការណ៍ថាឪពុកធ្វើទាហាន ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ពាក់សក្តិធំចេះចុះគេចាប់ខ្ញុំបណ្តោយ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	គេចាប់ខ្ញុំពូជោយប៉ែតមកចូលយើងចំការខ្មុរ ចំការខ្មុរផ្សារចំការគសព្វថ្ងៃនេះណាស់ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ចូលមកបានគេយកខ្ញុំទៅដាក់បន្ទាយនាង យកទៅដំបូងមិនទាន់ចងទេ យកខ្ញុំទៅបែកកង់នៅបត់ត្រង់ បែកកង់នៅបត់ត្រង់ដើរពីបត់ត្រង់ទៅដល់បន្ទាយនាងម៉ោងមួយបានដល់ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ដល់ទៅដល់យកខ្ញុំទុកហ្នឹងហើយទៅកន្លែងគុកគេវត្តបន្ទាយនាងហ្នឹង ។

ប៊ុនថនៈ	វត្តបន្ទាយនាង?

ជួនៈ	បាទ!វត្តបន្ទាយនាងកន្លែងគុកគេហ្នឹងណាស់ ខ្ញុំមិនដែលដឹងទេ ។

ប៊ុនថនៈ	ស្រុកអីវិញ?

ជួនៈ	ស្រុកមង្គលបូរីខ្ញុំមិនដែលដឹងទេ ខ្ញុំមិនដឹងថាគុកទេ ខ្ញុំទើបដឹងគុកកន្លែងនោះឯង ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ដែលខ្ញុំមកពីជោយប៉ែតមក មកដល់ចំការគមកដល់គ្រាន់តែឈប់ឡាន ពួកកូនឈ្លបគេចេះៗតូចមកផ្អែលឡាមហើយថា សុទ្ធពួកអាក្បត់ថាឲ្យខ្ញុំ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ថាពួកអាក្បត់ៗខ្ញុំមិនដឹងរឿងថាខ្លួនឯងក្បត់អីខ្ញុំអត់ដឹងខ្ញុំគ្មានបំណងក្បត់អីគេបន្តិចសោះណាស់អត់ដឹងរឿងទេ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ខ្ញុំមិនបានដឹងរឿងថាគេចាប់មកធ្វើអីទេ គេចាប់យើងគេមិនប្រាប់យើងថាម៉េចទេ ហៅថាមេឲ្យទៅរៀនទៅសូត្រនោះណាស់ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ហើយខ្មែរក្រហមចាប់ខ្ញុំវគ្គទី១ហើយណាស់ ។

ប៊ុនថនៈ	បាទ ។

ជួនៈ គេថាយកទៅរៀនទៅសូត្រ សម័យកាលនោះបើគេហៅមករៀនមកសូត្រយើងយល់ថាគេឲ្យយើងឡើងការងារអីដឹងចេះណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់មកចំការគស្សុទ្ធតែកាំភ្លើងអាកាសេ ៗ ថាសុទ្ធពួកអាក្បត់ៗខ្ញុំចប់បាត់ពាក្យអាក្បត់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់អ្នកយកខ្ញុំទៅឡានខូចនៅបត់ត្រង់ចេញតែកែងបត់ត្រង់រូបឡានខូចហ្នឹង ឡានខូចធ្វើម៉េចៗមិនរូបឡានអាស៊ីបអាដីពីដើមមិញ អាស៊ីបអងដី ។

ប៊ុនថនៈ បាទ ។

ជួនៈ ឡានចាស់សម្រាប់មេគេទៅយកយើង យើងអ្នកទោសនយោបាយគេដែលយកឡានល្អ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់ពេលឡានខូចនាំគ្នាដើរ ដើរដល់បន្ទាយនាងគេយកខ្ញុំទៅទុកគ្នាខ្ញុំប៉ុន្មាននាក់នោះ វ៉ៃគ្នាស្រែកអូយៗវ៉ៃគ្នាកន្ទែងគុកនិងណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំលបមើលគេឃើញសុទ្ធតែជាប់ខ្នោះ ។

ប៊ុនថនៈ ច្រើនទេ?

ជួនៈ ច្រើនណាស់ មួយអាគារវែងៗមួយកុដលោកដល់ខ្ញុំនិងរបៀបម៉េចដល់ពេលជួបហ្នឹងគាត់ហ្នឹងដែលពួកកងការពារឈ្មោះបងម៉ៅៗនៅ៣៣៥ វរៈគេនោះណាស់ កងពិសេសតាញឹមរស់ ញឹមនោះណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ៣៣៥ដល់ពេលហ្នឹងទៅគាត់ស្គាល់ខ្ញុំថាជួនឯងនៅជួបខ្ញុំនេះហើយមិនអីទេ ខ្ញុំថាបងម៉ៅខ្ញុំមានរឿងអីបានគេនាំខ្ញុំមកនេះ អើដឹង ចុះបើមិនដឹងរឿងបាននាំខ្ញុំមកនេះ ម៉ៅថាឯងមានធ្វើអីខុសដឹង ខ្ញុំថាខ្ញុំមិនដែលបានធ្វើអីខុសការងារខ្ញុំខំណាស់ ខ្ញុំនៅប៉ោយប៉ែតខ្ញុំជិរាបជូនប្អូនឯង ខ្ញុំតែស្រីនារីកងពួកកងនារីខ្ញុំឡើងទៅលើផ្ទះឡៅនោះខ្ញុំមិនដែលចង់ឃើញទេ ។

ប៊ុនថនៈ មាននារី?

ជួនៈ ហើយមេខ្ញុំថ្នាក់ដល់ធ្វើបាបខ្ញុំ ខ្ញុំអនាម័យខ្ញុំណាស់ ខ្ញុំដាំបាយដាំទឹកចេះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំដេកនៅលើចង់ធ្វើបាបខ្ញុំយកដេះមកដាក់និងទឹកខ្ញុំមេកងធំ ។

ប៊ុនថន: បាទ ។

ជួន: ឈ្មោះ អាណែនៗ និងមេកងធំខ្ញុំយកដេះទៅដាក់ទឹកយកទៅដាក់កែវប្រឡាក់ប្រឡុះដល់ហើយល្ងាចឡើងយកយើងទៅអប់រំថាមិនចេះអនាម័យអី ការពិតយើងស្អាតតែវាធ្វើបាបហ្នឹង ។

ប៊ុនថន: បាទ ។

ជួន: ទីបញ្ចប់អាណែនហ្នឹងត្រូវគ្រាប់ផាប់ ខ្ញុំហើយអ្នកលីយកវាពីថ្នល់ រទេះភ្លើងអាខាងត្បូងថ្នល់អារទេះភ្លើង វាត្រូវផាប់មិនទាន់ផាប់ទេខ្ញុំយកវាមកពីសមរភូមិមកឈាមឡាក់ទីបញ្ចប់បានខ្ញុំជាអ្នកយកមក ។

ប៊ុនថន: បាទ ។

ជួន: លីមកតាមផ្លូវដាច់ដង្ហើមស្លាប់ទទេ ស្លាប់ទៅដល់អាមេមួយទៀតមកធ្វើបាបខ្ញុំចេះទៀតហើយ ។

ប៊ុនថន: បាទ ។

ជួន: បានគេចោទខ្ញុំថាខ្ញុំសុទ្ធតែចេះ ខ្ញុំមិនដែលទេខ្ញុំសម្អាតអនាម័យ ផ្ទះខ្ញុំនិយាយឲ្យត្រង់ចេះនិយាយអួតទេ ប្រពន្ធខ្ញុំបើមិនចេះសម្អាតខ្ញុំថាបណ្ដោយបើមិនចេះសម្អាត ។

ប៊ុនថន: បាទ ។

ជួន: ពួកដែលធ្វើបាបខ្ញុំផាប់ទាំងអស់រលីង មេកងធំមេអីធ្វើបាបខ្ញុំផាប់ដោយបាបកម្មដឹង ។

ប៊ុនថន: បាទ ។

ជួន: ដល់ក្រោយមកចាប់ខ្ញុំដូចខ្ញុំជិះរាបដូនបួនឯងណាស់ រហូតដល់បន្ទាយនាង បន្ទាយនាងជួបម៉ៅ ម៉ៅស្រឡាញ់ខ្ញុំរាប់អានខ្ញុំដល់ខ្ញុំនៅបន្ទាយនាងប្រហែលជា១៥ថ្ងៃ គេមានឈ្មោះបញ្ជូនទៅនៅកំពីងយើង ខាងលិចភ្នំធំភ្នំតូចហ្នឹង ។

ប៊ុនថន: បាទ ។

ជួន: មិនចុះពីភ្នំធំមានប្រឡាយមួយទៅឃុំអូរប្រាសាទ ។

ប៊ុនថន: បាទ ។

ជួន: ឃុំអូរប្រាសាទទៅចូលទៅភូមិ“កស្វាយ” កន្លែងទម្លាប់ចំការដូងកន្លែងហ្នឹងគេវៃមនុស្សចោលច្រើនដាងគេ ។

ប៊ុនថន: បាទ ។

ជួនៈ ខ្ញុំនៅនោះអន្ទុងពួកខ្ញុំហ្នឹងហើយជាអ្នកជីកខ្ញុំទៅនៅនោះ អន្ទុងជីកប៉ុនៗស្រះនេះបើស្រះនេះពីរ ប៉ុនស្រះនេះធ្វើជាពីរតែគេជីកដាច់ជីកអន្ទុង ។

ប៉ុនថនៈ បាទ ។

ជួនៈ កន្លែងនេះសមរភូមិសម្លាប់មនុស្សចោលដែរ ស្រុកខ្ញុំមានសម្លាប់មនុស្សដែរ ។

ប៉ុនថនៈ ដូចថាអ្នកចោទពូហ្នឹង ចោទពូយ៉ាងម៉េចវិញ?

ជួនៈ ចោទថាខ្ញុំឪពុកធ្វើជាជាទាហាន ។

ប៉ុនថនៈ បាទ ។

ជួនៈ គេប្រាប់តែប៉ុណ្ណោះទៅគេស្រាវជ្រាវកូនដែលធ្វើទាហានដែលក្បត់សម័យនោះណាស់ ។

ប៉ុនថនៈ បាទ!អ្នកណាជាអ្នកចោទហ្នឹងពូ?

ជួន ស្លាប់ហើយឈ្មោះដួនដែលខ្ញុំនិយាយហ្នឹងឯង អ្នកស្រុកខ្ញុំនេះឯងស្លាប់ហើយយួនបាញ់ស្លាប់ ។

ប៉ុនថនៈ បាទ!ហើយកាលទៅបន្ទាយនាងហ្នឹងគេអត់មានដាក់?

ជួនៈ អត់មានដាក់ច្រវ៉ាក់ទេ គេយកខ្ញុំទៅកសាងខ្លួន ។

ប៉ុនថនៈ បាទ ។

ជួនៈ គេយកទៅដាក់កន្លែងកំពឹងគេយកយើងទៅកសាងខ្លួនទៅដល់នោះគេឲ្យខ្ញុំ ខ្ញុំពូកែដាំបាយដាំទឹកនោះ ។

ប៉ុនថនៈ បាទ ។

ជួនៈ គេឲ្យខ្ញុំនៅប្រធានកាស៊ីនដាំបាយ ។

ប៉ុនថនៈ បាទ ។

ជួនៈ កាន់ម៉ាកាស៊ីនបាយនិងឯង ខ្ញុំដាំបាយដាំអីដល់ក្រោយមកនេះមានគេរត់គេលួនទៅគេចោទខ្ញុំថាជាមេខ្លោងដឹកនាំរត់ថ្ងៃនោះដឹងថាគេចោទខ្ញុំដោយសារអីទេ ឈ្មោះ ឡាត់ជាប្រធានមន្ទីរឈ្មោះឡាត់ៗហ្នឹងគាត់ប្រជុំគោលការណ៍របស់គាត់យកប្រជុំឯកសារ៨៧០របស់មជ្ឈឹមនោះណាស់ ។

ប៉ុនថនៈ បាទ ។

ជួនៈ មកលើកគោលការណ៍ប្រជុំរឿងកងចល័តទាំងអស់ រឿងការអភិវឌ្ឍន៍របស់គេធ្វើស្រែប៉ុន្មានតោនណាស់ ។

ប៉ុនថនៈ បាទ ។

ជួនៈ ដល់ហើយប្រជុំចប់គេលើកស្ម័យទិទៀន ។

ប៊ុនថន: បាទ ។

ជួនៈ ហើយខ្ញុំឯកភាពកងចល័តទាំងអស់កុមារកងស្រួចតាំងកុមារទាំងកងចល័តយុវ័យយើង នេះ ។

ប៊ុនថន: បាទ ។

ជួនៈ ទាំងអស់ឲ្យខ្ញុំណែនាំប្រធានហ្នឹងឯង ប៉េឡាត់និងណាស់ ។

ប៊ុនថន: បាទ ។

ជួនៈ យើងណែនាំហើយដាក់ខ្លួនឲ្យគេទិទៀនណាស់ ស្ម័យនិទៀនៗខ្ញុំលើកគោលការណ៍ខ្ញុំសុំមាន យោបល់ សូមគោរប្រធានអង្គប្រជុំនិងសូមគោរពអស់លោកសមមិត្តដែលជាថ្នាក់ដឹកនាំ កងចល័តទាំងអស់ ថ្ងៃនេះឲ្យខ្ញុំមានយោបល់ជូនលោកប្រធាន ។

ប៊ុនថន: បាទ ។

ជួនៈ និយាយរឿងការហូបចុក ការហូបចុកហ្នឹងមិនមានរឿងអីវែងឆ្ងាយទេ គ្រាន់ថាបងប្អូនសុំ ឲ្យធ្វើអីម្ហូបដែលឲ្យធ្វើហ្នឹងឲ្យសមរម្យបន្តិចចែកគ្នាបានរស់ផង ។

ប៊ុនថន: បាទ ។

ជួនៈ កងចល័តឲ្យគ្នាហូបកាត់ត្រកួនប្រវែងនេះដូចជ្រូក ខ្លួនឯងកាត់ខ្ទីៗស្ងោរឆ្នាំងតូចឲ្យហូប ។

ប៊ុនថន: បាទ ។

ជួនៈ គេឮតែប៉ុណ្ណឹងឯង គេបិតសាវនាការជូងគេបែរខ្នងដាក់បណ្ដោយបិតអង្គប្រជុំគេដើរហួច ថ្ងៃរ ។

ប៊ុនថន: មាននិយាយអី?

ជួនៈ អត់មាននិយាយអីទេ ខ្ញុំឮតែប៉ុណ្ណោះ និយាយតែប៉ុណ្ណោះបិតអង្គប្រជុំគ្រីប ។

ប៊ុនថន: បាទ ។

ជួនៈ គេហួច ដល់ហួចខ្ញុំដឹងថាគេចាប់ខ្ញុំបាត់ គ្នាខ្ញុំប្អូននាក់ដែលគេត្រូវចាប់ ប្អូននាក់មេកងតូច ហើយខ្ញុំប្រធានកាស៊ីនបាយហ្នឹង ។

ប៊ុនថន: បាទ ។

ជួនៈ ខ្ញុំអាវុធ អាជឿន អាប៊ុនគ្នាប្អូននាក់ ។

ប៊ុនថន: បាទ ។

ជួនៈ គេចាប់មួយថ្ងៃហ្នឹង ពីថ្ងៃគ្រាន់តែគេហួចចេញរួចគេទៅរាយការណ៍នៅមន្ទលបូរីគេបកមកវិញគេប្រាប់ខ្ញុំថាគេផ្ញើលិខិតថាមេហៅសមមិត្តឯងទៅប្រជុំនៅមន្ទលបូរី ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំដឹងថាគេចាប់ខ្ញុំបាត់ហើយ ខ្ញុំអង្រឹងខ្ញុំពណ៌ត្រួយចេកខ្ញុំមិនបានយកអីទេ ខ្ញុំនឹកឃើញថាខ្លាចរងារ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្លាចខ្ញុំហូតខ្សែចេញអស់ដឹងថាខ្លួនឯងដឹងថាជាប់គុកបាត់ហើយដល់គេហៅខ្ញុំទៅជាប់ប្រជុំមិត្តអាបីនាក់មិនទៅទេ ទៅតែខ្ញុំមួយគត់គេថាណាខ្លះទៀតខ្ញុំថាអត់បានដឹងផងមិនដឹងជាទៅណាណីហើយ ទៅតែមួយទៅកើតដែរ ចុះទៅកន្លែងសិនទៅចឹង ដល់ទៅកន្លែងវិញសិនស្រាប់តែយប់ងងឹតៗម៉ោង៦កងទ័ពមកដល់ឈឹប គេនៅជុំវិញខ្លួនបាត់ ជុំវិញកន្លែងខ្ញុំនៅ ។

ប៊ុនថនៈ បាទ ។

ជួនៈ កងចល័តគេហៅខ្ញុំ ហៅឈ្មោះពួកខ្ញុំមកអាមួយនៅកន្លែងចំការីមទារ ដល់ពេលនេះទៅខ្ញុំឡើងដល់អន្លុយគេប្រជុំគេនិយាយ អាមួយទៀតមិនទាន់មកដល់ទេ គេឲ្យកំលាំងគេដឹងហើយ អានោះគេឲ្យកំលាំងគេទៅយកពីនោះហើយ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់ពេលឡើងទៅគេអន្លុយលេង មុនដំបូងគេសំណោះសំណាលពីរឿងចេះចុះគេលើកឡើងណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ គេនិយាយដូចយើងនិយាយចេះណាស់ ដល់ពេលក្រោយមកបានគេចូលទៅក្នុងមួយភ្លេតគេប្រាប់ឲ្យនេះមកផ្តងពួកខ្ញុំ ដល់អានោះមកដល់ហើយ អានោះមកដល់ភ្លាមអានោះស្រែករ៉ាកៗមានរឿងអីបានចាប់ខ្ញុំអានោះទាត់ពួកឈ្លប មិត្តវ៉ុធទាត់ពួកឈ្លបរ៉ាវៗពួកហ្នឹងផ្តងខ្ញុំជាប់និងពាងខ្ញុំអន្លុយអែបពាងចេះដឹងអីគេមកផ្តងចឹង ។

ប៊ុនថនៈ ចឹងពូអត់តដៃទេ?

ជួនៈ អត់ទេ ខ្ញុំអត់ទេ ខ្ញុំថាចាប់ខ្ញុំរឿងអីគេហួចទៀតហើយ គេហួចខ្សែវគេចាប់ខ្ញុំចងគ្រឹបៗខ្ញុំថាមានកំហុសអីដែលចាប់ ថាមិនបាច់និយាយទេ បើគ្មានកំហុសមានពីរណាគេចាប់ទេ ខែនោះទឹកជន់បានពួកក្មេងកងចល័តដែលខ្ញុំដាំបាយឲ្យហូបគ្រប់គ្នា គេថាខ្ញុំស្លាប់បាត់ហើយថាខ្ញុំយកវៃចោលចំការដូងបាត់ហើយកន្លែងចំការដូងនោះណា ។

ប៊ុនថន៖ បាទ ។

ជួន៖ ទីបញ្ចប់បញ្ជូនខ្ញុំមកចង់ខ្ញុំឲ្យគឹងដើរតាមប្រឡាយស្រែកទឹកផងទិនផឹកចេះវេទនាណាស់ ឡើងស្គឹកដៃអស់មកដល់ឡើងឡានអាស៊ីបគេចាំនៅដាប់ថ្នល់ កាលនោះមិនមានសាលារៀនមួយសព្វថ្ងៃផ្លូវបំបែក សាលារៀនភ្នំធំនោះ ។

ប៊ុនថន៖ បាទ ។

ជួន៖ ភ្នំធំនោះមានសាលាអនុវិទ្យាល័យគេមួយ ។

ប៊ុនថន៖ បាទ ។

ជួន៖ ខ្ញុំទៅភ្នំពេញខ្ញុំប្រាប់ម៉ែវាថា គេចាប់ខ្ញុំត្រង់នេះឯង ។

ប៊ុនថន៖ បាទ ។

ជួន៖ ចាប់ខ្ញុំទៅដល់បាត់ដំបង ទៅដល់បាត់ដំបងនៅម៉ោង៣ទៅដល់ចូលកន្លែងគុកបាត់ដំបងទៅដាក់គ្រឹប១ ខ្ញុំអង្គុយចេះគេដាក់ខ្នោះជើង បងម៉ៅដូចខ្ញុំថាគាត់ទៅដល់វេះខាងនោះផង ការពារកន្លែងសន្តិសុខមួយភូមិភាគនោះគាត់ប្រធាន ។

ប៊ុនថន៖ បាទ ។

ជួន៖ ដល់ទៅដល់ឃើញខ្ញុំម៉េចបានដាមកនៅនេះទៀតហើយ ចុះគេចាប់ខ្ញុំ ខ្ញុំមិនដឹងផងដល់សួរខ្ញុំខ្ញុំថា មើលលោកឡាត់ប្រជុំឯកសារគណៈមជ្ឈិម៨៧០កងចល័តឲ្យខ្ញុំលើកឡើងពីបញ្ហាហូបចុកកាត់ត្រកួនវែងត្រកួនខ្លីគេបិតអង្គប្រជុំរាយការណ៍ចាប់ខ្ញុំមកបណ្ដោយ មិនអីទេចុះពួកហ្នឹងវីងមកចាប់ប៊ុ ឡាត់វៃចោលបណ្ដោយ ចាប់ប៊ុឡាត់វៃចោលទៅវិញប្រាប់ខ្ញុំទាំងយប់ពីបាត់ដំបងមកលឿនមែនទែនណាស់ ទៅវិញដាក់ចោលហើយហ្នឹង ផ្ញើបាបតែគ្នាឯង ។

ប៊ុនថន៖ បាទ ។

ជួន៖ ខ្ញុំជាប់គុកនៅបាត់ដំបង២៨ខ្ញុំមិនទាន់ជឿថាគេវៃចោលទេ វៃចោលមេដែលរាយការណ៍ខ្ញុំនោះណាស់ ដែលរាយការណ៍ចាប់ខ្ញុំនោះ ។

ប៊ុនថន៖ បាទ ។

ជួន៖ ថាវៃចោលហើយមិនទុកទេ កាលសម័យនោះគេរកខ្សែយួន ប៊ុ ឡាត់នោះប្រពន្ធយួន ។

ប៊ុនថន៖ អ ។

ជួន៖ បាទ!ខ្សែយួន ។

ប៊ុនថន៖ ពូម៉ៅជាមួយពូហ្នឹងស្គាល់គ្នាតាំងពីពេលណាមក?

ជួន៖ ស្គាល់គ្នាតាំងពីសម័យតស៊ូកាលណាកាណឹ កាលនោះតូចច្រិ១ ។

ប៊ុនថន៖ គាត់នៅភូមិឃុំណាដែរ?

ជួន៖ គាត់នៅភូមិណាមិនស្គាល់ទេ ស្គាល់តែកាលពីនៅជុំគ្នាទៅដែលដើរចុះគេនៅភូមិភាគណាស់គេកងពិសេស ។

ប៊ុនថន៖ បាទ ។

ជួន៖ គេគ្រប់គ្រងការងារទៅមនុស្សដូចគេចេះតែយល់ទៅ មនុស្សល្អណាស់មនុស្សចេះនោះឈ្មោះ ម៉ៅៗសព្វថ្ងៃមិនដឹងជាទៅណាមិនដែលជួប ។

ប៊ុនថន៖ និយាយថាគាត់ស្គាល់តាំងពីយូរកាលជំនាន់ចូលជាខ្មែរក្រហម?

ជួន៖ បាទ ។

ប៊ុនថន៖ ចឹងគាត់ស្គាល់តាំងពីពេលចូលតស៊ូ?

ជួន៖ បាទ!ស្គាល់តាំងពីនិងទៅដល់ទៅបានជួបគាត់ កាលពីសម័យខ្ញុំនៅយោធាជុំគ្នានោះណាស់ ។

ប៊ុនថន៖ បាទ ។

ជួន៖ ពិសេសភូមិភាគគាត់ដើរមើលកងវរៈខ្ញុំនៅប៉ោយប៉ែតស្គាល់ខ្ញុំដល់ក្រោយមកខ្ញុំរាយការណ៍ជាប់ទៅខ្ញុំជាប់គុកនៅបាត់ដំបង២៨ថ្ងៃ ខ្ញុំគេឆក់ខ្សែភ្លើងពីមើមមិញរោមខ្ញុំបោចម៉ាស្រឡាញ់ ។

ប៊ុនថន៖ បាទ ។

ជួន៖ សព្វថ្ងៃមិនទាន់បាត់ឈឺមែនទែនផងបោច ។

ប៊ុនថន៖ ស្ពឹកដែលពូ?

ជួន៖ ស្ពឹកអស់ ។

ប៊ុនថន៖ បាទ ។

ជួន៖ អាប៊ុ ធួនៗ អាធួនហ្នឹងវាខាងព្រហ្មទណ្ឌគេអ្នកសួរចំលើយខ្ញុំ ។

ប៊ុនថន៖ បាទ ។

ជួន៖ ខ្ញុំឆ្លើយថាខ្ញុំមិនដែលដឹងទេ គ្នាខ្ញុំប៉ុន្មាននាក់មើលខ្ញុំឆក់ខ្សែភ្លើង ពួកអស់នោះសុទ្ធតែវៃគ្នាខ្ញុំមានបួននាក់ វាមិនដឹងរឿងមែនហ្នឹង សួរថាអ្នកឯងក្បត់ប្រុងដឹកកំលាំងទៅថៃប៉ុន្មាននាក់ៗខ្ញុំមិនដែលដឹងទេ ។

ប៊ុនថន៖ បាទ ។

ជួន៖ ខ្ញុំឆ្លើយថាខ្ញុំមិនដឹង ខ្ញុំមិនដឹងហ្នឹង ខ្ញុំឆក់ខ្សែភ្លើងពីរដង ខ្ញុំសន្លប់ដួងកៅអីគឹងៗ ប្រកាច់ដាក់ទ្រឹតៗក្បាល អស់រលីងហើយសន្លប់ទៅតែដឹងខ្លួន ហើយដាក់សំពត់ភ្លៀងពីរដង ឆក់ខ្សែ

ភ្លើងដួលគ្រាំងទៅគ្រាន់ទេ បើអ៊ុតសំពត់ភ្លៀងប្អូនអើយ សំពត់ភ្លៀងដាក់ទៅវាចូលប្រមុះអស់មានដកដង្ហើមណារួចអាមាត់ក៏ចូលប្រមុះក៏ចូលនោះ ។

ប៊ុនថន: ដាក់កៅស៊ូយឺតៗហ្នឹង?

ជួន: បាទ!ដល់ខ្ញុំទៅគេឲ្យយើងឆ្លើយ ហើយឆ្លើយយ៉ាងម៉េចរួចបើមាត់ហាមិនរួចចូលអស់ ។

ប៊ុនថន: បាទ ។

ជួន: គេដកចេញទៅទំរាំបានដឹងខ្លួនវិញ គេសួរទៀតខ្ញុំឆ្លើយមិនដឹងសួរអស់ចិត្តអត់មានបានវៃខ្ញុំទេ តែឆក់ខ្សែភ្លើងនិងអ៊ុតសំពត់ភ្លៀងខ្ញុំណាស់ ។

ប៊ុនថន: បាទ ។

ជួន: បើផុតពីនោះគេវៃដល់ក្រោយមក ។

ប៊ុនថន: គេហៅគុកអីវិញពូ?

ជួន: គុកនៅបាត់ដំបងនៅវត្តកណ្ដាល ។

ប៊ុនថន: គេហៅគុកតំបន់ឬគុកអីវិញ?

ជួន: គុកតំបន់ ។

ប៊ុនថន: តំបន់ប៉ុន្មាន?

ជួន: តំបន់៥ ។

ប៊ុនថន: តំបន់៥ ?

ជួន: តំបន់៤បាត់ដំបងភូមិភាគកន្ទែហគុកភូមិភាគ និយាយរួមភូមិភាគ ភូមិភាគពាយ័ព្យ ។

ប៊ុនថន: បាទ ។

ជួន: គុកភូមិភាគពាយ័ព្យ ។

ប៊ុនថន: ចឹងពីណាជាអ្នកគ្រប់គងនៅហ្នឹងពូ?

ជួន: អ្នកគ្រប់គ្រងនៅនោះខ្ញុំដឹងថា ប៉ិ នោះឈ្មោះ ប៉ិ ម៉ៅ ខ្មោចល់ព្រំយើងដូចទ្រី ។

ប៊ុនថន: បាទ ។

ជួន: ពីដើមខ្ញុំឃើញ សម័យ៧៩ខ្ញុំទៅឃើញដើរ ចកញក់ៗខ្មោមនុស្សស្ដេចល្វង់ណាស់ ។

ប៊ុនថន: បាទ ។

ជួន: អ្នកឆក់ខ្សែភ្លើថខ្ញុំឈ្មោះ អា ធួន ខ្ញុំនិយាយកាត់ទៅមុខឆ្ងាយបន្តិច ខ្ញុំមកនៅនេះវិញមើលមិនទាន់និយាយដល់ដំណាក់កាលខ្ញុំបានប្រពន្ធទេ ខ្ញុំនៅនេះបានប្រពន្ធខ្ញុំ មេឃុំនេះខ្ញុំរកស៊ីលក់អីវ៉ាន់ ខ្ញុំទៅទិញឥវ៉ាន់មង្គលបូរីមកលក់គេចំពាក់ប្រាក់ខ្ញុំទៅទារចិនគេចោទ គេចោទ

ទៀតហើយ ថាខ្ញុំនិងបំរុងដឹកកាំភ្លើងទៅបូន់ក្រោម សម័យប៉ុរាដែលស្គាល់អាភាពនៅទ្រា នេះទេ ទៅទិញឥវ៉ាន់នៅមន្ទលបូរីនិយាយប្រាប់ខ្ញុំ ដល់ខ្ញុំទៅទារប្រាក់នោះចោទខ្ញុំ ខ្មោចតាព្រៀងមេឃុំនេះចោទខ្ញុំ ។

ប៊ុនថន: បាទ ។

ជួន: ខ្ញុំរត់ទៅធ្វើខ្មែរក្រហមទៀត ខ្ញុំទៅដល់គេដឹងប្រវត្តិយើងធ្វើខ្មែរក្រហមគេមិនឲ្យយើងធ្វើមេកាលហ្នឹង ។

ប៊ុនថន: បាទ ។

ជួន: ឲ្យតែបានទៅនោះ ។

ប៊ុនថន: បាទ ។

ជួន: ទៅធ្វើមេឃើញប៉ុ ធួនដែលឆក់ខ្សែភ្លើងខ្ញុំនិរសាខ្ញុំសុំបាញ់តែខ្ញុំមិនឲ្យបាញ់ សុំបាញ់តា តាពែកលក់គុយទាវនៅភូមិទោល ។

ប៊ុនថន: ចឹងជួបពូនិយាយចូលប្អូមួយយ៉ាងម៉េច?

ជួន: ឃើញខ្មោចខ្ញុំដើរតែព័តកាលខ្ញុំប្រាប់និរសាខ្ញុំថា អាត្រាថា អានេះឆក់ខ្សែភ្លើងអញកាលសម័យនោះ វាថាបាញ់ទៅបង បាញ់បេដាក់មួយគ្រាប់ងាប់ហើយខ្ញុំថាកុំឲ្យមានបាបកម្មយើងនៅក្រោមការគ្រប់គ្រងរបស់គេយើងកុំទៅធ្វើចឹង ។

ប៊ុនថន: បាទ ។

ជួន: បើឲ្យតែវាបាញ់មួយគ្រាប់ងាប់បាត់ហើយដាក់ដាច់ពូជបាត់លែងលក់គុយទាវលែងនៅសល់ហើយសម័យនោះមានច្បាប់អីណា ។

ប៊ុនថន: បាទ ។

ជួន: ខ្ញុំមិនដែលទេ ខ្ញុំមានតែមេត្តាទៅវិញ ។

ប៊ុនថន: ពូទៅជួបនៅណា?

ជួន: ជួបនៅព្រៃមាន់យើងនេះ ព្រៃមាន់យើង ។

ប៊ុនថន: តែរាល់ថ្ងៃមាននៅរស់ទេ?

ជួន: មិនដឹងជាទៅណាទេ កាលនោះមិនដឹងជាផ្លើលរត់ទៅនៅណាទេ ។

ប៊ុនថន: បាទ ។

ជួន: តែឃើញខ្ញុំមានទាហានអីអត់ហ៊ានទៅទេ ។

ប៊ុនថន: បាទ ។

ជួន: ឈ្មោះវ៉ា អាធួន១ មើលអានក់ខ្សែភ្លើងដៃនោះកាលនោះកុងតាក់ចេះឯង ។

ប៊ុនថន: បាទ ។

ជួន: ខ្ញុំអង្គុយដូចប្អូនឯងចេះឯង ។

ប៊ុនថន: បាទ ។

ជួន: គ្រាន់សួរម៉េច១ភ្ជាមដៃដាក់ទ្រឹតទៅដួលគ្រាំងអង្គុយធ្វើប្រងើយខ្ញុំក្រោកឡើងដឹងខ្លួនសួរទៀតដាក់ទ្រឹតទៀត ។

ប៊ុនថន: សួរពូប៉ុន្មានថ្ងៃពូ?

ជួន: សួរចំលើយខ្ញុំឆក់ខ្សែភ្លើងពីរដង អ៊ុតសំពតភ្លៀងពីរដងដល់វគ្គក្រោយថ្ងៃសួរចំលើយខ្ញុំថាឆ្លើយឲ្យងាប់តែម្តងមើលទៅវេទនាណាស់ បាយកេះគ្រាប់ប៉ុននេះលាយឆ្នាំងខ្ទះគេដាក់ប៉ុនណាណីគេដាក់បាយតែបន្តិចគេចាក់ទឹកដាក់និងស្ងាប់ព្រាគេនិងសង្កីសី កេះគេអាកេះគ្រាប់យើងនោះ ។

ប៊ុនថន: បាទ ។

ជួន: កេះគ្រាប់ដាក់មកផ្អែមអស់អំបិលស៊ីអំបិលគ្រោះផ្អែមអត់មានអំបិលប្រៃទេ ។

ប៊ុនថន: បាទ ។

ជួន: អាផ្អែមប្រៃចុងអណ្តាតផ្អែមចុងអណ្តាតដូចយើងដាក់ប៊ីចេងម៉ាល្អមនិងណាស់ ។

ប៊ុនថន: បាទ ។

ជួន: ហត់គ្រូក១ដល់ថ្ងៃនោះគេបើកខ្ញុំដឹង តែបើគេកាន់ខ្សែមកដែលខ្ញុំគិតថាខ្ញុំងាប់បាត់ហើយដល់គេយកក្រដាសមកកាន់ក្រដាសចេះ គេហៅឈ្មោះ ម៉ាន់ ជួន ខ្ញុំឆ្លើយបាទ គេឲ្យយកសោទៅដោះខ្ញុំមក ។

ប៊ុនថន: បាទ ។

ជួន: ដោះចេញមកហៅឈ្មោះគ្នាខ្ញុំទាំងអស់ប្អូននាក់ ឈរអែបជញ្ជាំងសាលារៀនគេថតខ្ញុំទាំងអស់គ្នា គេសួរខ្ញុំគេសួត្ររបាយការណ៍ណាស់ ថាយើងមានទោសមានពៃរ៍អីណាស់ ។

ប៊ុនថន: បាទ ។

ជួន: គេថាសុំទោសគេនិយាយណាស់ សមមិត្តកំហុសដែលជាគុកនេះដោយសារឈ្មោះ សមមិត្តឡាត់ជាប្រធានគ្រប់គ្រងយល់ច្រឡំធ្វើតាមពាក្យគេធ្វើដោយមិនប្រក្រតីណាស់ ។

ប៊ុនថន: បាទ ។

ជួនៈ	គេនិយាយទៅមេខាងលើគេឲ្យដោះឲ្យទៅកសាងខ្លួនទៀត និយាយទៅក៏ដោះខ្ញុំប៉ុណ្ណោះ គឺលោកឡាត់នោះអស់ច្រើនណាស់ទៅហើយ កំហុសគាត់ផ្សេងដោយឡែក ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ខ្ញុំគេដោះលែងយកខ្ញុំទៅបំប៉នមួយអាទិត្យ គេបំប៉នណាស់ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ត្រីរសគេធ្វើម្ហូបឆ្ងាញ់គេបំប៉នខ្ញុំពួកខ្ញុំបួននាក់ហ្នឹង ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ដល់រួចមកគេយកពួកខ្ញុំទៅនៅកកោះមោងយើងនេះណាស់ ។

ប៊ុនថនៈ	កកោះ?

ជួនៈ	ឃុំកកោះ ស្រុកមោង ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ទៅនៅកកោះខ្ញុំទៅនៅកកោះខ្ញុំទៅដល់ភ្នាមមួយយប់មួយថ្ងៃទៅដល់ជួបចៅហ្វាយស្រុកឈ្មោះ តា ថុនៗ ដល់ហើយគេផ្ដាំផ្ញើរនោះទៅ គាត់រងភូមិភាគដែលជូនខ្ញុំទៅ ។

ប៊ុនថនៈ	គាត់រងភូមិភាគទៀត?

ជួនៈ	បាទ!រងតា ញឹម ។

ប៊ុនថនៈ	គាត់ឈ្មោះអីវិញ?

ជួនៈ	គាត់ឈ្មោះស្អីទេ...ឈ្មោះអីទេ រង តា ញឹមហ្នឹង គាត់ចិត្តល្អណាស់ ខោអាវខ្ញុំទាំងប៉ុន្មាននៅណាយកមកឲ្យខ្ញុំវិញទាំងអស់ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	គាត់ជួយខ្ញុំគាត់យកទៅឲ្យវិញ កុំពិបាកភ័យខោអាវគេចាប់ទាំងប៉ុន្មានគេយកមកឲ្យវិញ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ហើយទៅផ្ញាំផ្ញើរជាមួយតា ថុនថា តា ថុនឯងមើលផងពួកនេះមិនមានកំហុសអីទេ សុទ្ធតែអ្នកដឹកនាំល្អៗណាស់ គ្នាមិនដែលស្អីទេ គេចោទទេបានគ្នាជាប់គុកជាប់ប្រវ៉ាក់គាត់ប្រាប់តា ថុនចឹង ទៅដល់ពួកខ្ញុំបីនាក់សុទ្ធតែប្រធានកងចល័តនៅខ្ញុំមួយនិងឯងមិនទាន់ព្រុថាអីទេ ។

ប៊ុនថនៈ	បាទ ។

ជួនៈ បីថ្ងៃពួកខ្ញុំទៅមុនដំបូងមិនទាន់រៀបភ្នាមទេ បានបីថ្ងៃឲ្យចូលការងារជាមួយពួកកន្លែងនោះ មានគុកគេដាក់ដូចគ្នា គេដាក់ខ្នោះអាកន្លែងខ្នោះក៏មាន អាកន្លែងដេកលាតក៏មានកងចល័តទូទាំងកកោះហ្នឹងណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ មានអាកន្លែងគុកវៃគ្នាព្រឹកល្ងាចក៏មាន មានអាទៅស្រែទាត់គ្នាធ្លាក់ពីលើភ្លឺក៏មានពលកម្មការងារយ៉ាងម៉េច អាប៊ិ ស៊ី ម៉ែអាកាច ។

ប៊ុនថនៈ ស៊ីហ្នឹងគាត់ធ្វើអី?

ជួនៈ អាប៊ិ ស៊ីហ្នឹងប្រធានគ្រប់គ្រងការងារគេដើរមើលអាណាធ្វើការមិនធ្វើការ ។

ប៊ុនថនៈ បាទ ។

ជួនៈ គេហៅអាពួកឈ្លបគេនោះណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ឧទាហរណ៍ថាប្អូនឯងបេះ កងចល័តបេះមិនបានធ្វើការគេស្ទូងឯងលែងមកអង្គុយនៅតាមភ្លឺអីៗអានោះដើរមកដល់ទាត់ធ្លាក់ពីលើភ្លឺ ។

ប៊ុនថនៈ បាទ ។

ជួនៈ ម៉ាដើងមាំុងខ្មៀកហ្នឹងឯងហ៊ានតដៃចាប់គ្រឹបឥឡូវហ្នឹង ។

ប៊ុនថនៈ បាទ ។

ជួនៈ គេឈ្លបគេប្រធានឈ្លប ដល់ពេលពួកខ្ញុំដឹងថាខ្លួនឯងចុះគេឲ្យវែកកណ្ដាប់ប្អូនអើយដងវែកសុទ្ធតែសម្រួចខាងនេះខាងនោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ កណ្ដាប់ប៉ុនៗនេះនោះចាក់គ្រឹបៗ គ្រឹបវែកដាក់ៗដល់ឃើញយើងសកម្មការងារគេលើកយើងធ្វើមេ ម៉ាគ្នាខ្ញុំគេឲ្យធ្វើប្រធានកងចល័តទាំងអស់ប្អូននាក់សុទ្ធតែប្រធានអត់មានក្រោមគេទេ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់ខ្ញុំដល់ថ្នាក់គេយកឲ្យធ្វើអីទេ ខ្ញុំនៅតែឯងបីបួនថ្ងៃដល់ទីបញ្ចប់គេឲ្យខ្ញុំធ្វើលេខាខ្ញុំក្ដាប់លើពួកនោះទៀត ម៉ាកកោះនោះកងចល័តមាន៧វរៈ ការរដ្ឋានប៉ុន្មាននោះលើខ្ញុំ ខ្ញុំកាន់ឃ្លាំងអង្ករកាន់អីខ្ញុំបានរស់នោះហើយ ។

ប៊ុនថនៈ បាទ ។

ជួនៈ របាយការណ៍ខ្ញុំសរុបសិត្តិទាំងអស់ ធ្វើស្រែមួយថ្ងៃបានប៉ុន្មាន ព្រឹកបានប៉ុន្មាន កំលាំងប៉ុន្មានរាយការណ៍ឲ្យគេនៅក្រចកតូចរាយការណ៍ឲ្យចៅហ្វាយស្រុក ។

ប៉ុនថនៈ លេខាស្រុកចឹង?

ជួនៈ បាទ! កាលនោះគេហៅលេខាចល័តណាស់ ។

ប៉ុនថនៈ បាទ ។

ជួនៈ លេខាចល័តខ្ញុំចល័តតែម្ដង គេឲ្យខ្ញុំចល័ត ។

ប៉ុនថនៈ បាទ ។

ជួនៈ ទាំងសហករណ៍ទាំងអីចល័តគេឲ្យសេះខ្ញុំមួយកង់ខ្ញុំមួយរាយការណ៍ធ្វើការទាំងយប់ប្រកួតជាមួយអាប៉ិ នីម១មួយរករឿងខ្ញុំទៀត មិនដឹងធ្វើម៉េចខ្ញុំឲ្យដួលខ្ញុំទៀតធ្វើមិនបាន ខ្ញុំធ្វើការសកម្មដែរ ។ របាការណ៍ខ្ញុំធ្វើច្បាស់ដែរ ។

ប៉ុនថនៈ បាទ ។

ជួនៈ ស្រែក្នុងមួយថ្ងៃស្ទូងបានប៉ុន្មាន ព្រោះបានប៉ុន្មាន ដកប៉ុន្មាន កំលាំងប៉ុន្មាន ឈឺប៉ុន្មានខ្ញុំធ្វើសិត្តិរាយការណ៍ សម័យនិងសរសេរតែដៃនោះ ។

ប៉ុនថនៈ បាទ ។

ជួនៈ មិនដែលមានអី អត្តលីលេខមានគេស្រុក ឲ្យខ្ញុំទៅរៀនអត្តលីលេខទៀត តែខ្ញុំមិនដែលបានទំនេរ ដល់អាប៉ិ នីមនោះប្រកួតខ្ញុំទៀត ដល់ក្រោយមកគេការប្រពន្ធឲ្យខ្ញុំ ប្រពន្ធដើមខ្ញុំមិនមែនប្រពន្ធនេះទេ ។

ប៉ុនថនៈ បាទ ។

ជួនៈ ប្រពន្ធដើមខ្ញុំនៅពោធិសាត់កំពង់ឆ្នាំងនោះ ការប្រពន្ធខ្ញុំទៅកើតស្រុកវៀតណាមចូលនេះឯងហ្នឹង ។

ប៉ុនថនៈ បាទ ។

ជួនៈ វៀតណាមចូលនេះហើយទៀត ខ្ញុំដើរតាមក្រោយនេះឯងរថក្រោះមកនេះជាប់ជ៉ោងក្ដឹង១ក្រេវ១កាលនោះយើងមិនដែលដឹងរឿងណា ។

ប៉ុនថនៈ បាទ ។

ជួនៈ ស្មានតែកងទ័ពយើងតើ ដល់នេះគេថាយួន១ មានអីគេចតែខ្លួនប្រុចរត់ ។

ប៉ុនថនៈ បាទ ។

ជួនៈ រត់ហើយអីហើយគេរៀបចំកំលាំងបានទៅទៀត គេឲ្យខ្ញុំធ្វើកងទ័ពទៀត កងទ័ពទៀតខ្ញុំវ៉ៃម្តុំភ្នំប៉ាដេរវ៉ៃជាមួយយួនណា ។

ប៊ុនថនៈ បាទ ។

ជួនៈ និយាយឲ្យត្រង់សម្តែងការស្មោះត្រង់តែម្តង ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំកើតមេបញ្ជាការរងកាំភ្លើងធំពីភ្នំប៉ាដេរហូតមកដល់សាលាសកលបាត់ដំបង ខ្ញុំវ៉ៃចូលដល់សាលាសកលណាស់ ។

ប៊ុនថនៈ កាលហ្នឹងពូនៅ?

ជួនៈ នៅខាងខ្មែរក្រហម ។

ប៊ុនថនៈ នៅខាងខ្មែរក្រហមកងវរៈអីប៉ុន្មាន?

ជួនៈ កាលនោះអត់ដឹងថាវរៈប៉ុន្មានទេ រៀបឲ្យតែបានៗវ៉ៃទទឹងទទែងវ៉ៃឲ្យតែបានៗមិនមានវរៈអីទេ ។

ប៊ុនថនៈ តែមេពូ?

ជួនៈ គ្រាន់តែរៀបប្រចាំមួយស្រុកនោះឯង ម៉ាស្រុកមោងម៉ាកកោះណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ តា ចៅហ្វាយស្រុកគាត់រៀបចំឲ្យ គ្រាន់តែវ៉ៃប៉ុណ្ណោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ កាលនោះអាពួកកុកសៗចេញមក ដោយសារអាពួកកុកសហ្នឹងឯងវ៉ៃចេញពីក្រោយគ្រឹបអាពួកមកពីនិរតីចោទ ថាពួកខ្ញុំវ៉ៃគេ ចោទថាពួកខ្ញុំវ៉ៃគេយកពួកខ្ញុំទៅសម្លាប់ចោលនៅកំពង់គយើងនេះនៅអន្លង់វិលនេះ កាលនោះអន្លង់វិលកំពង់គកាច់រទេះហ្នឹង ។

ប៊ុនថនៈ បាទ ។

ជួនៈ អស់៩០ផ្លាយនាក់ ។

ប៊ុនថនៈ ខាងនិរតីចូលមក?

ជួនៈ បាទ!សម្លាប់ចោលពួកខ្ញុំអស់៩០ផ្លាយនាក់ខ្ញុំប្រាប់ ។

ប៊ុនថនៈ កាលហ្នឹងវៀតណាមចូលមកហើយនៅ?

ជួនៈ	កាលហ្នឹងវៀតណាមចូលមកហើយ វៀតណាមចូលកំពង់តែវ៉ៃគ្នានិងឯងអាពួកនេះវ៉ៃគ្នាឯងទៀត អាពួកនិរតីចោទពួកឯងថាពួកឯង ពួកឯងពួកអាក្បត់ៗអីវ៉ៃពួកវាទៀត ចាប់ពួកខ្ញុំអស់៩០នាក់ជាង ។

ប៊ុនថនៈ	ចឹងពូ ពូរត់?

ជួនៈ	គេតាមចាប់ខ្ញុំ ខ្ញុំដឹងខ្លួនចាំមើលខ្ញុំមេ ខ្ញុំដល់ពេលថ្ងៃនោះរបួសច្រើនខ្ញុំនាំគ្នាឯងពួកម៉ាកខ្ញុំនិងរកមើលពួកទាហានយើងមានរបួសខ្លះដឹង ទៅភ្នំប៉ារដេ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ទៅដល់មន្ទីរពេទ្យរបួសគ្នាវា អាពួកហ្នឹងបោកគ្រាប់បែក គេហៅទៅតម្រង់ជួរៗចាប់ចងបណ្ដោយ ចាប់ចងអានោះមានគ្រាប់បែកបោកបណ្ដោយត្រូវគ្នាវាអាពួកនិរតីហ្នឹងរបួសដេកពេទ្យដល់ខ្ញុំទៅដល់ ម៉េចវ៉ៃណាបានជារបួសហ្នឹង ចុះខ្ញុំទៅមើលទាហានខ្ញុំដែលនោះ ។ កាលនោះពួកកកោះឯងបាត់ខ្សែឯងបាត់ ខ្ញុំថាគោះម៉ាកមិនបាច់នៅទេ ប្រុចពួសួរថាពួកកកោះពួកណាវ៉ៃគ្នាឯងទេ ថាពួកអាក្បត់ៗពួកអាពាយ័ព្យចុះឯង ចឹងថាដឹងវ៉ៃឯងបាត់ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ពួកហ្នឹងដេញចាប់ខ្ញុំ និយាយពីឡានមករកឆ្លាចពួកមេវាឈ្មោះ អា ប៊ុ ឈនៗនៅម៉ាខ្សែសព្វថ្ងៃហ្នឹងឯង ។

ប៊ុនថនៈ	ឈ្មោះ អីឈន?

ជួនៈ	ឈ្មោះ អីឈនទេ មេកងពល សព្វថ្ងៃគាត់កងពលអា ប៊ុឈនៗហ្នឹង ។

ប៊ុនថនៈ	នៅកងពលណា?

ជួនៈ	នៅម្ដុំនៅនោះឯង មិនដឹងជានៅណាទេ ខ្ញុំមិនដែលបានរកអាប៊ុ ឈនដែរ ។

ប៊ុនថនៈ	បាទ ។

ជួនៈ	ឈ្មោះ អា ឈនៗ ។

ប៊ុនថនៈ	ឈ្មោះ អី ឈនកាលហ្នឹងឈ្មោះពេញ?

ជួនៈ	មិនដឹងទេ មិនស្គាល់ទេ តែពួកគេអាកាមួយដើមកាំភ្លើងខ្លីមួយដើម សាហាវណាស់ពួកនោះបើវ៉ៃគ្នានខ្មោចទេ កាលនោះរបួសត្រូវគ្រាបលវៀតណាមនៅសាលាសកលហ្នឹងសែងមិនអស់ ។

ប៊ុនថនៈ	បាទ ។

ជួនៈ ខ្ញុំការភ្លើងធំខ្ញុំខ្ទុសេតផងផងមិនចោលមួយគ្រាប់ទេ កូនទាហានខ្ញុំមានរបួសម្នាក់មួយផង ដល់ទីបញ្ចប់គេរកសម្លាប់ខ្ញុំ ខ្ញុំគេចបានប្រុចទៅស្រុកប្រពន្ធខ្ញុំនៅលាច ទៅលាចយួនចាប់បានទៀត ។ កាលហ្នឹងខ្ញុំកើតពីសដៃផង យួនចាប់បានយួនថា ទាហានប៉ុល ពត ទាហានកងទ័ពវៀតណាមបាញ់ត្រូវច្រកាងនេះឯង ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំថាអត់ទេ ថ្ងៃនោះចេះយួនចាប់បានកុំអីដេកមួយផ្ទះគ្នា២០ទៅ៣០នាក់ដឹង ។

ប៊ុនថនៈ បាទ ។

ជួនៈ ឆ្ងាយ ដល់ឆ្ងាយគេដកឫសផុចមកដេកស្រួលបាត់ឈឺ ដូចសំណាងខ្ញុំឈប់ធ្វើទ័ព ។

ប៊ុនថនៈ បាទ ។

ជួនៈ នាំប្រពន្ធខ្ញុំមកនៅស្រុកខ្ញុំនិងឯងដល់មកនៅខ្ញុំចាប់ផ្ដើមមករកស៊ីណាស់ ។

ប៊ុនថនៈ ចឹងពូមកនៅផ្គាំវិញ?

ជួនៈ បាទ!មកនៅផ្គាំ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់មកនៅផ្គាំវិញមេឃុំចោទខ្ញុំ ថាខ្ញុំទាក់ទងលួចប្លន់គេហ្នឹងឯង ខ្ញុំទីងរត់ដេញចាប់ខ្ញុំនោះវៀតណាមដេញចាប់ខ្ញុំ អ្នកដែលចាប់ខ្ញុំសួរប៉ុ ស្រីមនេះ ស្រីមថាខ្ញុំមានអីហ្នឹងថាជួនពូកែមែន ថាខ្ញុំប្អូនខ្ញុំសព្វថ្ងៃខ្ញុំនាំទៅប្អូនខ្ញុំនៅនេះឯង ប្រពន្ធអាគីនេះ ។

ប៊ុនថនៈ បាទ ។

ជួនៈ កាលនោះនៅលីវតូចមួយ នៅលីវកំពង់តែពេញដំទង់ពាក់អាវក្រហមខោ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំកូនខ្ញុំពីរនាក់ ។

ប៊ុនថនៈ បាទ ។

ជួនៈ អាកូនតូចមួយសព្វថ្ងៃបានប្រពន្ធកូនពីរបីហើយមីបងមួយ មីបងនៅធ្វើការភ្នំពេញសព្វថ្ងៃនោះ នាំដើរទៅយួនហំអស់ហើយប្អូន ។

ប៊ុនថនៈ បាទ ។

ជួនៈ ដល់កូនខ្ញុំយំតូច គ្រាន់តែស្រែកដំាប្របាច់កត្រឹបយួនហំអស់ហើយខ្ញុំគេចរួចចាប់ខ្ញុំមិនបានខ្លាំងអីចាប់ខ្ញុំមិនបានខ្ញុំគេចទៅនៅព្រៃមាន់ ។

ប៊ុនថនៈ បាទ ។

ជួនៈ នាំចូលកងទ័ពឲ្យខ្ញុំផ្ញើមេទៀត ។

ប៊ុនថនៈ បាទ!ប្រពន្ធពូទៅទេ ទៅទាំងអស់គ្នា?

ជួនៈ ប្រពន្ធខ្ញុំនោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ប្រពន្ធខ្ញុំនៅនេះ ។

ប៊ុនថនៈ អត់ទៅទេ ទៅតែពូរត់ទៅ កាលវៀតណាមដេញចាប់?

ជួនៈ កាលនោះមុនដំបូងខ្ញុំទៅហើយ ខ្ញុំទៅរួចខ្ញុំមកយកប្រពន្ធខ្ញុំដែលយួនដេញចាប់នោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ គេព្រួតែខ្ញុំមកយកប្រពន្ធបានជាគេដេញចាប់ហ្នឹង ខ្ញុំទៅមុនហើយខ្ញុំមកយកប្រពន្ធខ្ញុំ ។

ប៊ុនថនៈ បាទ ។

ជួនៈ យកប្រពន្ធរួចបានទៅនៅនោះទៅនៅរួចបានខ្ញុំមក ។

ប៊ុនថនៈ ចឹងនៅព្រៃមាន់ហ្នឹងពូចូលទៀត?

ជួនៈ ចូលទៅធ្វើកងទ័ពជាមួយប៉ែន វ៉ូយនេះ ។

ប៊ុនថនៈ ប៉ែន វ៉ូយ?

ជួនៈ ប៉ែន វ៉ូយ កងពល៨២ សុទ្ធតែគ្នាខ្ញុំហើយនិងនោះ ប៉ែន វ៉ូយមេៗសុទ្ធតែគ្នាខ្ញុំហើយ ។

ប៊ុនថនៈ គាត់ប្រធានកងពល?

ជួនៈ បាទ!ប្រធានកងពល ។

ប៊ុនថនៈ ចឹងពូនៅហ្នឹងដល់ឆ្នាំប៉ុន្មាន?

ជួនៈ ខ្ញុំនៅឡើងឆ្នាំ៨៥ ៨៥ខ្ញុំបានប្រពន្ធខ្ញុំនេះ បានប្រពន្ធខ្ញុំដោយសារវ៉ៃគ្នានិងយួនខ្ញុំមកស្គាក់វៀតណាមនៅទន្លេកំពីងពួយនេះ ដល់វៀតណាមរុលទៅមុខវ៉ៃប៉ះមេខ្ញុំបងវឿនៗប្រធានអនុប្រធានវរៈសេនាធំត្រូវត្រង់នេះធ្លាយមកត្រចៀកនេះ ។

ប៊ុនថនៈ បាទ ។

ជួនៈ យកមកដេកពេទ្យនៅកូនក្លែងខ្ញុំមកបេះដូងអីឲ្យទៅខ្ញុំមើលគ្នាឯងសុទ្ធតែគ្នាខ្ញុំកូនចៅឯងចង់បានបុណ្យសក្តិពីខ្ញុំណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ គេរកសម្លាប់ខ្ញុំគេឃើញមេរបួសខ្លាំងហើយមិនរស់ទេ គេរកសម្លាប់ខ្ញុំគេបំរ៉ុងបាញ់ខ្ញុំចោលដើម្បីយកមុខដំណែង ។

ប៊ុនថន៖ បាទ ។

ជួន៖ ទីបញ្ចប់ពួកហ្នឹងផាប់អស់ហើយ អាខ្លះស្លាយមិនទៅអត្តយមុខជណ្តើរអ្នកស្រុកផ្ទះមិនស្គរ ផាប់ អាខ្លះដើរលេលឺយួនបាញ់ផាប់អស់រលីងគ្មានសល់ទេ រស់តែខ្ញុំហ្នឹងឯង ។

ប៊ុនថន៖ បាទ ។

ជួន៖ ខ្ញុំមកបានប្រពន្ធខ្ញុំមកនៅស្រុកអាំងអើយសព្វថ្ងៃ ប្រពន្ធនោះនៅនោះម៉ែវាទៅលេង ។

ប៊ុនថន៖ ចឹងនៅហ្នឹងដូចថាមានខាងប៉ារាដែលវៃប៉ះជាមួយទាហានប៉ារាទេ?

ជួន៖ ប៉ារានិយាយទៅមិនទាន់ចប់ខ្ញុំចូលធ្វើប៉ារាដែលតើ រឿងអានោះឯងដែលមកនេះខ្ញុំមកធ្វើ ប៉ារា ធ្វើប៉ារាខ្ញុំនៅកាន់ទាហានម្ដុំត្រង់នេះវៃជាមួយខ្មែរក្រហមទៀត មកធ្វើប៉ារាវៃជាមួយ ខ្មែរក្រហមទៀត ។ នៅអន្លង់វែងក៏ខ្ញុំវៃ ។

ប៊ុនថន៖ បាទ ។

ជួន៖ អន្លង់វែងខ្ញុំវៃជាមួយខ្មែរក្រហមមេបញ្ជាការប៉ុណ្ណាណីខ្ញុំវៃឡើងបែកជាមួយ តា នៃ ខ្ញុំ នៅវៃអន្លង់វែងសួរប្រពន្ធខ្ញុំ ប្រាក់ខែកាលនោះ ប្រាក់ខែ«ខ-ច»មានពីណាចាយគេទុកឲ្យខ្ញុំ ប៉ុននេះនៅផ្សារកំពង់ថ្កូវខ្ញុំយកទៅដូរ អ្នកផ្សារដែលហ៊ានកំរើក ចុះខ្ញុំលែងទៅវៃខ្ទាំងប្រាក់ អីណា«ខ-ច»គេទុកឲ្យខ្ញុំមិនចាយយ៉ាងម៉េចត្រូវតែដូរឲ្យខ្ញុំដូរឲ្យ ។

ប៊ុនថន៖ បាទ ។

ជួន៖ បើមិនដូរ យកទៅដូរជាមួយរដ្ឋទៅមានពីណាដូរចាំខ្ញុំទៅរករឿងទៀត សុខចិត្តដូរឲ្យខ្ញុំសួរ ប្រពន្ធខ្ញុំកំណើតប្រពន្ធខ្ញុំអាមួយ មីមួយដែលកូនខ្ញុំទៅអាមេរិចអាមួយអាតូចដែលរៀននៅ ស្វាយរៀងនេះ ។ កូនខ្ញុំអាប្រុសអាហ្នឹងតូច ។

ប៊ុនថន៖ ចឹងមានរៀននៅស្វាយរៀងទៀត?

ជួន៖ ជាប់អាហាររូបករណ៍រៀននៅស្វាយរៀង ចប់១២នេះទៅដាក់អាហារូបករណ៍ទៅជាប់វា ដាក់ភ្នំពេញមួយ សៀមរាបមួយ ស្វាយរៀងមួយជាប់គណិត ជូនកូនទៅដាក់ស្វាយរៀង ហ្នឹង ។

ប៊ុនថន៖ ពូកាលចូលប៉ារានៅឆ្នាំណា?

ជួន៖ ខ្ញុំចូលប៉ារាខ្ញុំបានប្រពន្ធខ្ញុំតាំងពីឆ្នាំ៨៤ ។

ប៊ុនថន៖ ចឹងទៅព្រៃមាន់ហ្នឹងខាងប៉ារាឬខាងខ្មែរក្រហម?

ជួន៖ ខាងខ្មែរក្រហម កាលនោះខ្មែរក្រហមខ្ញុំចូលមើលឆ្នាំ៧៩-៨០-៨១ខ្ញុំធ្វើនៅនោះបានពីរ ឆ្នាំទេ ។

ប៊ុនថន: ៨១?

ជួន: បាទ!៨២-៨៣ ចុង៨៣ខ្ញុំត្រឡប់មកវិញហើយ ត្រឡប់មកវិញបានប្រពន្ធខ្ញុំបានកូនខ្ញុំកើត៨៥ហ្នឹង។

ប៊ុនថន: ចឹង៨៥បានពូចូលប៉ារ៉ា?

ជួន: បាទ។

ប៊ុនថន: យ៉ាងម៉េចបានពូចូលប៉ារ៉ាវិញ?

ជួន: ចូលប៉ារ៉ាកាលនោះមកដល់គេធ្លាប់យើងធ្វើកងទ័ព ដល់ហើយគេចេះតែមកហៅទៅណា។

ប៊ុនថន: បាទ។

ជួន: សម័យកាលនោះជាសម័យរបទាញប្រទេស មុនដំបូងគេរៀបចំឲ្យខ្ញុំធ្វើប្រធានសន្តិសុខត្រង់នេះ ខ្ញុំកាន់ម៉ាត្រានេះ។

ប៊ុនថន: បាទ។

ជួន: ម៉ាហ្នឹង៣០០នាក់ជាង ខ្ញុំកាន់ទាំងអស់។

ប៊ុនថន: ហ្នឹងខាងប៉ារ៉ា?

ជួន: បាទ!នៅជាមួយឯកឧត្តមញ៉ឹក ប៊ុនឆៃ។

ប៊ុនថន: បាទ។

ជួន: ម៉ាប៉ារ៉ាត្រង់នេះខ្ញុំកាន់ទាំងអស់ ឈ្លបកាំភ្លើងមានច្រើន៣០០ជាងខ្ញុំកាន់គ្រប់គ្រងទាំងអស់ត្រង់នេះមានចល័តចាំមើលណា ខាងនេះមានប៉ារ៉ាខាងហ៊ុនស៊ីនប៉ិចមានឯកឧត្តមសឺន សានមានខាងខ្មែរក្រហម។

ប៊ុនថន: បាទ។

ជួន: ខ្ញុំនៅប្រចាំនេះឯង ខ្ញុំទទួលម៉ាទីសខាងនេះទាំងអស់។

ប៊ុនថន: ចឹងមានបីចឹងពូនៅខាងមួយណា?

ជួន: ខ្ញុំនៅខាងហ៊ុនស៊ីនប៉ិច។

ប៊ុនថន: ចឹងនៅខាងប៉ារ៉ាហ៊ុនស៊ីនប៉ិច?

ជួន: បាទ។

ប៊ុនថន: ចឹងពីមុនមកពូមានដែលស្គាល់ទេ ដូចជាប៉ារ៉ាអីចឹង?

ជួន: ពីមុនចូលខ្ញុំស្គាល់ដែលតែខ្ញុំមិនបានចូលខ្ញុំនៅជាមួយខ្មែរក្រហម ខ្មែរក្រហមគេនៅតាំងពីដើមមក។

ប៊ុនថន: បាទ!ចឹងមានប៉ះគ្នាដែរ ដូចខាងប៉ារាជាមួយខ្មែរក្រហម?

ជួន: ប៉ះដែលតែខ្មែរក្រហមដែលនៅនេះប្អូនខ្ញុំសុទ្ធតែក្មេងៗកើតក្រោយ ។

ប៊ុនថន: បាទ ។

ជួន: គេរកស៊ីអីរកទៅខ្ញុំមិនដែលរកអីទេ ស្វរប្រពន្ធខ្ញុំទៅគេនៅខ្មែរក្រហមនោះ គេបេះដូញគោ បេះលួចគោពីក្រោមមកវៃស៊ី ពួកខ្ញុំមិនដែលទេ ខ្ញុំនៅត្រង់នេះ គេដាក់កុងត្រូឡានដឹកស្រូវ ឡានដឹកស្អីខ្ញុំមិនដែលវិរុអីណា ខ្ញុំអ្នកស្នេហាជាតិខ្ញុំថាអត់មានវិរុរឿងបេះៗទេ ។

ប៊ុនថន: បាទ ។

ជួន: ពួកគេគិតពីរឿងរកស៊ីដាក់មីនត្រូវជើងត្រូវអីតាមនេះ ។

ប៊ុនថន: បាទ ។

ជួន: នៅភូមិនេះ ។

ប៊ុនថន: បាទ ។

ជួន: ទាស់គ្នាដាក់មីន ខ្ញុំមិនដែលទេធ្វើព្រងើយខ្ញុំមិនដែលទៅរករឿងបានប្រាក់ពីណាមកចិញ្ចឹមកូនទាហានខ្ញុំទេ ។

ប៊ុនថន: បាទ ។

ជួន: គេឲ្យប៉ុណ្ណាស៊ីបាយប៉ុណ្ណោះទៅ ។

ប៊ុនថន: បាទ ។

ជួន: ខ្ញុំ' មិនដែលទៅវិរុទេ ស៊ើបសួរត្រង់នេះខ្ញុំមិនដែលទៅទេ ខ្ញុំធ្វើខ្មែរក្រហមក៏ខ្ញុំមិនដើរលួចប្លន់គេ ។

ប៊ុនថន: បាទ ។

ជួន: ខ្ញុំគិតឃើញថា ធ្វើម៉េចធ្វើទ័ពច្បាំងគ្នាតែជាមួយយួននិយាយពីរឿងស្នេហាជាតិ និយាយពីរឿងស្អីណាសង្គ្រាមបេះបុះទៅ ឲ្យច្បាំងបុះនិយាយរឿងរកស៊ីលួចប្លន់ឆក់ក្រដៀតខ្ញុំមួយជាតិមិនដែលបេះគេទេ ចឹងបានជាខ្ញុំឈឺក្បាលឈឺឆ្អាលអារឿងគេចោទខ្ញុំ ។

ប៊ុនថន: បាទ!ចឹងពូមកនៅនេះខាងវៀតណាមអីមានដែលចូលមកដល់ហ្នឹងទេ?

ជួន: វៀតណាមនៅ វៀតណាមម៉ែស្រឡាញ់ខ្ញុំវៀតណាម ខ្ញុំបានប្រពន្ធនៅនេះវៀតណាមត្រូវខ្ញុំណាស់ កូនខ្ញុំទៅអាមេរិចវាឡាប់កាលនោះវាថ្ងុះផង ស្វរប្រពន្ធខ្ញុំហើយបានសាច់ឆ្អែបេះវាដាស់ខ្ញុំកំពង់តែដេកឲ្យធ្វើសាច់ឆ្អែហូប សាច់ឆ្អែធ្វើអីក៏ហៅខ្ញុំហូបដែរ ។ វៀតណាមមកនៅនេះ កាលខ្ញុំមកចូលស្រុកវិញត្រូវគ្នានិងវៀតណាមនិងតើ ។

ប៊ុនថន៖ បាទ ។

ជួន៖ មិនដែលបានរឿងរ៉ាវអីនិងវៀតណាមទេ គេមានរឿងរ៉ាវខ្ញុំមិនដែលអីទេ មិនដែលរឿងរ៉ាវជាមួយវៀតណាមទេ ។

ប៊ុនថន៖ បាទ!ចង់និយាយថា កាលពូនៅជាមួយប៉ារាហ្នឹងក្នុងភូមិហ្នឹងខាងវៀតណាមដែលវៃចូលមកប៉ះគ្នាទេ?

ជួន៖ មិនដែលទេ ខ្ញុំមិនដែលទេ ខ្ញុំមិនដែលបានវៃតាមនេះមិនដែលបានទេ ដល់ខ្ញុំមកធ្វើទ័ពនៅនេះតើ បានខ្ញុំបានវៃជាមួយខ្មែរក្រហមវិញ ។

ប៊ុនថន៖ ចឹងពូចូលទ័ពខាងក្នុងហ្នឹងឆ្នាំប៉ុន្មានហើយបានពូចូល?

ជួន៖ ខ្ញុំចូលទ័ពខាងក្នុងតាំងពីចូលពេញសិទ្ធចូល ខ្ញុំមកពីនោះវិញមើលឆ្នាំ៨៧ ។

ប៊ុនថន៖ ៨៧?

ជួន៖ បាទ ។

ប៊ុនថន៖ ចេញពីប៉ារាពូ?

ជួន៖ បាទ!ចេញពីប៉ារាចេញពីខ្មែរក្រហមមក ។

ប៊ុនថន៖ បាទ ។

ជួន៖ ចេញមកក៏ធ្វើទ័ពខាងក្នុងប៉ារាហ្នឹងឯងទ័ពខាងក្នុងហ្នឹងឯង ។

ប៊ុនថន៖ បាទ!ទ័ពខាងក្នុងប៉ារា?

ជួន៖ បាទ!ចូលកាលធ្វើសមាហរណ៍កម្មហើយណា ។

ប៊ុនថន៖ បាទ ។

ជួន៖ ដែលគេចូលមកជុំគ្នាណា ។

ប៊ុនថន៖ ធ្វើបានប៉ុន្មានឆ្នាំពូប៉ារា?

ជួន៖ ធ្វើបានឡើងមិនតិចខ្ញុំកាត់រំសាយតើ ខ្ញុំកាត់ជនពិការខ្ញុំបើកប្រាក់រាល់ខែតើ ។

ប៊ុនថន៖ បាទ ។

ជួន៖ ខ្ញុំនៅក្របខ័ណ្ឌរដ្ឋាភិបាលឯកឧត្តមតា បាញ់ឆ្នាំ២០០០ ។

ប៊ុនថន៖ បាទ!នៅខាងប៉ារាឆ្នាំណាអស់ពូនៅហ្នឹង?

ជួន៖ សមាហរណ៍កម្មកាលនោះមិនដឹងជាឆ្នាំប៉ុន្មានចេះ ប៉ារាអស់កាលនោះប្រហែលជាឆ្នាំ៩១-៩២ហ្នឹង មករួបរួមជាតិបោះឆ្នោត ។

ប៊ុនថន៖ បាទ ។

ជួនៈ ៩១-៩២ កាលនោះ៩០-៩១-៩២ហ្នឹងឯងមករួបរួមគ្នាដើម្បីបោះឆ្នោត ។

ប៊ុនថនៈ ចឹងចូលខាងប៉ុលពតប៉ុន្តែខាងខ្មែរក្រហមនៅ?

ជួនៈ ខាងខ្មែរក្រហមនៅ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្មែរក្រហមទើបធ្វើសមាហរណ៍កម្មក្រោយទេ ខ្ញុំចូលមកបានខ្មែរក្រហមធ្វើសមាហរណ៍កម្ម ខ្ញុំបានមកដុតហើយនោះ ។

ប៊ុនថនៈ បាទ!ចឹងនិយាយថាប៉ុលពតបានបោះឆ្នោតហើយពូបានមកនៅឃុំនិងវិញ?

ជួនៈ បាទ ។

ប៊ុនថនៈ ចឹងពីមុនមក?

ជួនៈ ខ្ញុំមកជួយតាំងពីនៅបោះឆ្នោត ខ្ញុំបោះឆ្នោះតាំងពី៩៣ ។

ប៊ុនថនៈ បាទ ។

ជួនៈ បោះឆ្នោតដែលឈ្នះសម្តេចក្រុមព្រះខ្ញុំហើយ ។

ប៊ុនថនៈ បាទ ។

ជួនៈ ដំហរនៅនេះប្រមូលកំលាំងបោះឆ្នោតឈ្នះសម្តេចក្រុមព្រះកាលនោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ទៅបោះនៅថ្មពួកទាំងឡាន១ទៅ កាលនោះខ្ញុំជាមេបញ្ជាការនៅត្រង់នេះ ។

ប៊ុនថនៈ ចឹងពូនៅតំបន់នេះពូមានដឹងថាស្ថានភាពយ៉ាងម៉េចដែលនៅតំបន់នេះ និយាយថាក្រោយ ៧៩ហើយនៅក្នុងភូមិហ្នឹងពូ?

ជួនៈ ៧៩ហើយក្នុងភូមិនេះអត់ទេ និយាយរឿងតំបន់នេះជាតំបន់ប្រទាញប្រទង់ដ៏ធំមួយបំផុត សម័យវៀតណាមចូលមកកាលឆ្នាំ៧៩ ក៏ប្រទាញប្រទង់ជាមួយខ្មែរក្រហមជាមួយប៉ុលពត ដល់ក្រោយមកសមាហរណ៍កម្មនឹងគ្នា សមាហរណ៍កម្មចូលប៉ុលពតនេះមកហើយក៏ពិបាកបាន ត្រូវគ្នាមួយសារនោះក៏បែកបាក់គ្នាទៅវិញទៀតទៅ ។ វាមានអាខ្សែឲ្យប៉ុលពតដកកាំភ្លើងខ្មែរ ក្រហមកាលនោះហ្នឹង ។

ប៊ុនថនៈ បាទ ។

ជួនៈ ហើយកើតប្រទុសសារាយបែកបាក់ខ្មែរក្រហមមួយសារទៀត នៅនេះប្រទាញប្រទង់រហូត ទើបស្រួលខ្មែរក្រហមចូលមកហ្នឹងបានស្រួល ទើបខ្មែរក្រហមធ្វើសមាហរណ៍កម្មរួចបាន ស្រួលរហូតសព្វថ្ងៃ ។

ប៊ុនថន៖ បាទ!ចឹងដូចថាប្រជាជនរស់នៅសន្តិសុខអីពិបាកទេ?

ជួន៖ សន្តិសុខកាលពីដើមឡើយគឺលំបាកណាស់ លំបាកបើនិយាយរឿងក្នុងឃុំនេះលំបាកណាស់ដូចនេះដូចភូមិកំណើតបើនិយាយរឿងឃុំនេះវាមានការសម្លាប់រស់ភាគតិចបើនិយាយដូចភូមិម៉ៅខាងនោះវិញ សម្លាប់គ្នាដោយខ្មែរក្រហមច្រើនដែរ ពួកខ្មែរក្រហមដែលបានប្រពន្ធនៅភូមិហ្នឹងឲ្យតែធ្វើលើបន្តិចស្លាប់ហើយ ។ សម្លាប់គ្នាតែម្តងរកស៊ីទាស់គ្នាសម្លាប់គ្នា បើមានអ្នកមានចឹងវាសន្តិសុខ សម័យអត់ច្បាប់អត់ទម្លាប់ណាអូន ។

ប៊ុនថន៖ បាទ ។

ជួន៖ នេះឃើញតែខ្ញុំមានកាំភ្លើងកាន់ ថាមកនៅស្រុកខ្ញុំថាវាងលើបន្តិចបាញ់ចោលអស់ច្រើនដែលតើ ។

ប៊ុនថន៖ ចឹងដូចជាអត់មានខាងណាកាន់ច្បាស់លាស់ទេ?

ជួន៖ អត់មានពីណាកាន់ទេ ទោះបីអ្នកធ្វើមេឃុំឲ្យតែគេថាធ្វើៗធ្វើមេឃុំដូចជាទីងមោង ។

ប៊ុនថន៖ បាទ ។

ជួន៖ ធ្វើអត់មានសិទ្ធដូចសព្វថ្ងៃទេ ពីដើមមិញធ្វើមែន ធ្វើមេឃុំគណបក្សប្រជាជនខាងព្រៃរករឿង ធ្វើមេឃុំខាងព្រៃខាងក្នុងរករឿងពិបាកចឹងឯង ។

ប៊ុនថន៖ បាទ ។

ជួន៖ ម្លោះហើយវាប្រទាញប្រទង់គ្នាវាពិបាកណាស់អូនឯងអត់មានឯករាជ្យដូចសព្វថ្ងៃ សព្វថ្ងៃមានតែមួយមានពីណា ពិតមែនក្រុមប្រឹក្សាឃុំវាមានគណបក្សចូលរួមផ្សេងក៏វាអត់មានអីជងការងារវានៅក្នុងការគ្រប់គ្រងមេឃុំតែមួយ ។ នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលតែមួយយើងហៅអ៊ីយើងត្រូវតែទៅណាស់ ។

ប៊ុនថន៖ បាទ ។

ជួន៖ វាមានការរិះគន់គ្នាបន្ទាប់បន្សំវាស៊ីសងលើបុគ្គលយើងអ្នកដឹកនាំគេធ្លាប់ធ្វើក្រុមប្រឹក្សាឃុំដូចខ្ញុំមិនដែលបានចូលរួមជាមួយក្រុមប្រឹក្សាឃុំ ។

ប៊ុនថន៖ ចឹងខាងនេះអត់មានពីណាគ្រប់គ្រងច្បាស់លាស់ទេ កាលជំនាន់ហ្នឹងពូ?

ជួន៖ កាលហ្នឹងអត់មានពីណាគ្រប់គ្រងច្បាស់លាស់ទេ ។

ប៊ុនថន៖ តែការរកស៊ីអីយ៉ាងម៉េចដែរ?

ជួន៖ កាលរកស៊ីកាលហ្នឹងបើបុគ្គលណាហ៊ានរកស៊ីបុគ្គលនោះបាន ។

ប៊ុនថន៖ បាទ ។

ជួនៈ ដូចពួកខ្ញុំម៉េច ចេះជំនួញជួញប្រែខាងរកស៊ីលក់ក្របីទិញក្របីរកបានណាស់កាលនោះ ពី ព្រោះគេអ្នកខ្វាចអត់ហ៊ានរកយើងអ្នកហ៊ានរកបាន ដល់បច្ចុប្បន្នរកស៊ីដើមធំមែនតែ ចំណេញតូច ។

ប៊ុនថនៈ ទៅលក់ខាងណា?

ជួនៈ ទៅលក់ទល់ដែន ម្កាក់តាខ្សាបឹងត្រកួនយើងនេះ ។

ប៊ុនថនៈ ចឹងលក់ឲ្យថៃវិញ?

ជួនៈ បាទ!រកបានចំណេញបានកម្រៃតែពិបាកជួនកាលមួយខ្សែទៅប៉ះពួកឈ្លបគេស្ទាក់បាញ់ទៅ បែកបាក់ទៅខ្ញុំកំសត់ណាស់គេបាញ់ប៉ុន្មានដងនៅតែអាយុមិនអស់ទៅ ចេះតែបានរស់សព្វ ថ្ងៃទៅ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្លះត្រូវមីនទៅរបួសងាប់គោងាប់ក្របី លំបាកណាស់ប្អូនអើយការរកស៊ីឆ្លងកាត់អាយុប៉ុន នេះមកដំណាក់កាល៣០ឆ្នាំនេះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ស្គាល់រស់ជាតិអស់ហើយតឹងតែង ។

ប៊ុនថនៈ ចុះលោកពូមកនៅនេះនៅពេលបោះឆ្នោតហ្នឹងមានស្គាល់ឌុចគាត់នៅហ្នឹងដែលពូមានស្គាល់ ទេ?

ជួនៈ តា ពិនបើនិយាយខ្ញុំមនុស្សនេះនិងខ្ញុំរាប់អានគ្នាមែនទែនស្គាល់ខ្ញុំស្គាល់ច្បាស់តែម្តង ។

ប៊ុនថនៈ បាទ ។

ជួនៈ តែខ្ញុំមិនបានដឹងថា តា ពិនជាខ្មែរក្រហមគាត់ធ្វើជាប្រធានគុកទួលស្លែងមិនដែលដឹងទេ ។

ប៊ុនថនៈ បាទ ។

ជួនៈ គាត់មកដូចជាឃើញខ្ញុំចេះសន្តានចិត្តគាត់រាប់អានខ្ញុំ ។

ប៊ុនថនៈ បាទ ។

ជួនៈ គាត់រាប់អានខ្ញុំគាត់ស្គាល់ខ្ញុំយកចិត្តទុកដាក់និងខ្ញុំ ខ្ញុំស្គាល់គាត់យកចិត្តទុកដាក់និងគាត់ចេះឯង បើមានអីចែកគ្នាពីព្រោះគាត់ មនុស្សគាត់ចេះចឹងតែឃើញខ្ញុំ ខ្ញុំទៅលេងផ្ទះគាត់ចេះអង្គុយ និយាយលេងតែមិនដែលនិយាយរឿងហ្នឹងទេ និយាយតែពីការសិក្សារកស៊ី ។

ប៊ុនថនៈ បាទ ។

ជួនៈ ធ្វើម៉េចឲ្យល្អគាត់និយាយ អត់មាននិយាយរឿងខ្មែរក្រហមអត់ទេ ។

ប៊ុនថន: ចឹងគាត់ចូលមកនៅឆ្នាំណាពូ?

ជួន: កាលនោះមិនដឹងជាឆ្នាំណាទេ ។

ប៊ុនថន: មុនពូឬក្រោយពូ?

ជួន: មកក្រោយខ្ញុំ គាត់មកពីហ្នឹងកាលប្អូនខ្ញុំអាថេងវានៅផ្ទះនេះដែលប្អូនឯងហូបបាយ ។

ប៊ុនថន: បាទ ។

ជួន: កាលហ្នឹងពួកហ្នឹងទៅនៅព្រំប្រទល់ហើយ ។

ប៊ុនថន: បាទ ។

ជួន: គាត់ទៅក្រោយខ្ញុំតើ ដល់គាត់មកវិញនេះឃើញនាំតា នេះមកមានប្រាក់ទិញឡាន អាឡានឆ្នៃយើងមកពីថៃ អាឡានដូកៗណាស់ ស្រុកគេនោះគេហៅអាដូកៗឡានឆ្នៃដូចឡានបោកស្រូវខ្ញុំតែឡានគេធ្វើបានស្អាតហើយគេមានប្រាក់ទិញម៉ាស៊ីនស្រូវ ។

ប៊ុនថន: បាទ ។

ជួន: មុនរបរគាត់ទេណា គាត់មកនៅបានយូរតែខ្ញុំគ្រាន់តែស្គាល់ទេ ផ្ទះខ្ញុំនៅត្បូងនោះអែបលោកគ្រូប៉េង ប៉ុននោះគាត់ក៏ជាបងខ្ញុំជីដូនមួយដែរ ។

ប៊ុនថន: បាទ ។

ជួន: អាថេងនេះប្អូនខ្ញុំជីដូនមួយសុទ្ធតែខ្សែសាឡាយពូជពង្ស ។

ប៊ុនថន: បាទ ។

ជួន: ថេងនេះម្ដាយគាត់និងឪពុកខ្ញុំបងប្អូនបង្កើត បើគ្រូប៉េង ប៉ុននោះឪពុកគាត់និងម្ដាយខ្ញុំបងប្អូនបង្កើត ។

ប៊ុនថន: បាទ ។

ជួន: ហើយដល់ពេលហ្នឹងទៅ តា នេះនៅនេះគាត់មិនដែលមានបញ្ហាអីទេ ចឹងទៅនៅទៅឃើញគាត់ល្អគាត់ជាអ្នកចេះដឹងជ្រើសរើគាត់ជាគ្រូ ។

ប៊ុនថន: បាទ ។

ជួន: ធ្វើជាគ្រូបង្រៀនណាស់ ។

ប៊ុនថន: ចឹងគាត់មកពីជំរំទេ?

ជួន: គាត់មកពីជំរំ ។

ប៊ុនថន: ជំរំអីវិញពូ?

ជួនៈ មិនដឹង មិនដឹងជាជំរំអីទេ មកពីណាទេ តំបន់ខ្មែរក្រហមមកពីនោះដឹងមិនដឹងស្អីខ្ញុំមិនដែលដឹងទេ ។

ប៊ុនថនៈ បាទ ។

ជួនៈ គាត់ដឹងមនោសញ្ចេតនាដែលស្គាល់គាត់ដោយសារតែនិយាយលេងសំណេះសំណាលពីរឿងសីលធម៌ពីរឿងការរកស៊ីចេះឯង អត់មាននិយាយខ្ញុំនៅនេះធ្វើចេះធ្វើអីអត់ទេ និយាយរឿងខ្មែរក្រហមមិនដែលបាននិយាយទេ ។

ប៊ុនថនៈ ចឹងគាត់ដើរសួរពូទេ មានសួរពូថាធ្វើអីទេ?

ជួនៈ មិនដែលសួរទេ គាត់ដឹងថាខ្ញុំខ្សែខ្មែរក្រហមដែរ កាលមុននោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ធ្លាប់ធ្វើខ្មែរក្រហមតាំងពីយូរដែលនោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ គាត់មិនដែលនិយាយអី ដល់ក្រោយមកប្រវត្តិប្រពន្ធគាត់ស្លាប់ខ្ញុំអ្នកដឹងរឿង ខ្ញុំអត់ដឹងរឿងថា គាត់ដឹងខ្លួនថាប្អូនគាត់ទេ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំនេះ តា ង៉ុយយើងនេះ តា ង៉ុយគាត់មកធ្វើទាហានជាមួយតា ផ្កាន តា ង៉ុយនេះជួបខ្ញុំកាលហ្នឹងខ្ញុំនៅជាទាហានដែរ ខ្ញុំទៅជួបគាត់ គាត់ថាជួន គេថាតា ពិនគេថាមានណាស់មកពីខ្មែរក្រហមមានមាសប៉ុន្មានគីឡូយកទៅផ្ញើរណាខ្លះគេដឹងអស់ទៀតចេះឯង ។ មានមាសផ្ញើរនៅផ្ទះអ្នកនេះប៉ុននេះ ផ្ទះនោះប៉ុណ្ណោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ថាខ្ញុំធ្វើម៉េចចុះ គេឲ្យប្អូនខ្ញុំថាម៉េចទៅប្អូនអីគាត់ចុះ ខ្ញុំដឹងរឿងពីនោះមកទេ ខ្ញុំមកប្រាប់ប្រាប់នោះមិនទាន់ប្រាប់សាមីខ្លួនទេ ប្រាប់មេឃុំ ប្រាប់មេឃុំ ព្រៀង ប្រាប់បងគង់នេះឯង កាលហ្នឹងបងគង់គាត់ធ្វើជាជំទប់ណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ជួន គង់ៗនោះគាត់ធ្វើជាជំទប់ ព្រៀងធ្វើជាមេឃុំ ខ្ញុំប្រាប់បងឯងឲ្យយាយម៉ៅប្រយ័ត្នផងព្រោះដំណឹងគេប្រាប់មកខ្ញុំ ខ្ញុំមិនដែលដឹងទេថាយាយម៉ៅមានមាសទាំងគីឡូពីខ្មែរក្រហមមាសទាំងគីឡូចោរវាររកប្អូនហើយ គេដាក់ខ្សែប្អូនខ្ញុំថាខ្សែប្អូនមានពីណាមានតែម្ចាស់គេផ្ញើរមាសនិងហើយទាក់ទងឲ្យប្អូនមែនន៍ ។

ប៊ុនថន:	បាទ ។

ជួន:	បេះឯង ។

ប៊ុនថន:	ចឹងកាលហ្នឹងមានបោះឆ្នោតហើយនៅពូ?

ជួន:	បោះឆ្នោតរួចហើយ៩៣ ។

ប៊ុនថន:	តាមពិតមានមាសមែនទេ?

ជួន:	ខ្ញុំមិនបានដឹងរឿងថាគេមានមាសប៉ុន្មានផង ។

ប៊ុនថន:	បាទ ។

ជួន:	តាមស៊ើបដំណើរមានមែនតែមិនដឹងជាមានប៉ុន្មានទេ ។

ប៊ុនថន:	បាទ ។

ជួន:	គាត់មានគាត់ទិញម៉ាស៊ីនស្រូវ គាត់ទិញឡានតាដែនអីមុខរបរគេរកស៊ីមិនគេមានប៉ុន្មានទេ ហើយចោរដែលប្លន់នោះ ដល់ខ្ញុំទៅប្រាប់មេឃុំគេថាដឹងយូរណាស់ហើយខ្មិលគេចដែលថា ដែលស្គាល់ផ្ទះ តា ង៉ាតយូរហើយ ដែលបានសម្គាស់តា ង៉ាតទេ ។

ប៊ុនថន:	អត់ដែលផង ។

ជួន:	ឡូត ង៉ាតៗ សព្វថ្ងៃគាត់ទៅនៅអីឈៀននោះ តាមពិតទៅដេកផ្ទះគាត់ប៉ុន្មានយប់ចង់ដឹង សួរគាត់ទៅ ។

ប៊ុនថន:	បាទ ។

ជួន:	ឡើងខ្ញុំប្រាប់យាយម៉ៅ យាយម៉ៅថាគេចឡើងប៉ុន្មានហើយពូជួនអើយខ្ញុំគេចឡើងប៉ុន្មាន ឡើងខ្មិលគេចហើយ ស្រេចតែបានប៉ុន្មានយប់ឡើងយប់ជ្រៅខ្ញុំដេកផ្ទះខ្ញុំក្ដគេស្រែកហេគ្រាវ ថាគេប្លន់យាយម៉ៅងាប់បាត់ហើយ ខ្ញុំសម័យនោះមានខ្លាចអីផងដើរទៅសួរគ្នា ។

ប៊ុនថន:	បាទ ។

ជួន:	មកឃើញស្លាប់មែន តា នោះគេដឹកទៅថ្នូពួកបាត់ទៅអ្នករបួស ។

ប៊ុនថន:	ចុះកូនៗគាត់?

ជួន:	កូនគាត់នៅហ្នឹង ។

ប៊ុនថន:	កូនគាត់អត់នៅជាមួយគាត់ទេ?

ជួន:	នៅនេះទាំងអស់ កូនគាត់សព្វថ្ងៃមិនដឹងជានៅណា ។

ប៊ុនថន:	តែកាលហ្នឹងអត់មានធ្វើបាបកូនទេ?

ជួនៈ អត់អីទេ អាមួយតូច អាមួយប៉ុននេះម៉ែវាអាពៅគេប៉ុននេះឯង ចាក់គ្នាឡើងជិពុះទង់ធ្វើបាបគ្នា ខ្ញុំដល់ស៊ើបបន្តិចទៀតគេហៅខ្ញុំទៅសួរ ថាចោរប្អូននិយាយទៅប៉ះឯងអ្នករាយការណ៍ឲ្យហ្នឹង ។

ប៉ុនថនៈ ចឹងគេចង់ចោទ?

ជួនៈ ដែលខ្ញុំរាយការណ៍ជិទប់ហ្នឹងឯង គេថាជិទប់អ្នកប្អូននិងតែម្តង រៀបចំផែនការណ៍ប្អូនតែម្តងហ្នឹង ។

ប៉ុនថនៈ បាទ ។

ជួនៈ ប្អូនយាយម៉ៅសម្លាប់ កាលហ្នឹងគេយកបងគង់ទៅនោះ ទៅស្វាយចេកទៅអីនោះ ឯងជាអ្នកផ្តល់ពត៌មាន កាលនោះគេបំរ៉ុងថាអ្នកណាដឹងអ្នកនោះឯង គេចោទមកខ្ញុំវិញខ្ញុំថាអត់ទេខ្ញុំផ្តល់ពត៌មានឲ្យអាជ្វាធរខ្ញុំអត់មានលូកដៃខ្ញុំសួរប្រពន្ធខ្ញុំទៅ មិនដែលទេ ។

ប៉ុនថនៈ បាទ ។

ជួនៈ ខ្ញុំអ្នកផ្តល់ពត៌មានឲ្យហើយចោទខ្ញុំយ៉ាងម៉េចកើត ។

ប៉ុនថនៈ បាទ ។

ជួនៈ ចង់ប្រាសមកខ្ញុំវិញ ។

ប៉ុនថនៈ បាទ ។

ជួនៈ ឯកភាពបងប្អូនហៅខ្ញុំទៅស៊ើបសួរគួរដោះស្រាយយ៉ាងណា ខ្ញុំថាអត់ទេមានពីណាមានទោសទេ ។

ប៉ុនថនៈ បាទ ។

ជួនៈ អ្នកមានទុក្ខអ្នកនិងមានទោសហើយអ្នកណាប្រព្រឹត្តិអ្នកនិងមានទោសហើយខ្ញុំនិយាយចេះឯង ។

ប៉ុនថនៈ បាទ ។

ជួនៈ គ្រង់នេះឯងខ្មែរក្រហមអ្នកឯងឃាតករអីណា អ្នកណាឃាតករអ្នកនោះអ្នកណាគាមចោរចោរទៅខ្ញុំនិយាយចេះឯងពួកនោះទឹងខ្ញុំថាខ្ញុំនិយាយយករួចខ្លួន បើមិនរួចខ្លួនយ៉ាងម៉េច បើអ្នកឯងធ្វើបានអ្នកនោះមានកំហុសមែនណែស ។

ប៉ុនថនៈ បាទ!និយាយថាកាលហ្នឹងគេអត់មានបាញ់គ្នាទេ គេចាក់?

ជួនៈ គេចាក់ ។

ប៉ុនថនៈ អ្នកប្អូនមានគ្នាប៉ុន្មាននាក់?

ជួនៈ មិនដឹងជាប៉ុន្មានទេកាលនោះ ចាប់តែម្នាក់ទៅយកមេខ្មោងទៅ ។

ប៊ុនថនៈ និយាយគាត់គេបាញ់ត្រូវរបួសដែលឬមួយយ៉ាងណា?

ជួនៈ ពីណា ។

ប៊ុនថនៈ តា ពិនហ្នឹង?

ជួនៈ គាត់របួសដែលតើ កាលនោះមិនដឹងជារបួសត្រង់ណាខ្ញុំក៏មិនបានមើលគេយកទៅពេទ្យទៅ ចាក់គាត់ដែលតែគាត់ធ្វើជាស្លាប់ទៅ ។

ប៊ុនថនៈ គាត់ធ្វើជាស្លាប់?

ជួនៈ បាទ ។

ប៊ុនថនៈ ចឹងក្រោយពីនិងមកគាត់ទៅណាទៀត?

ជួនៈ ក្រោយពីហ្នឹងមកបានគេយកគាត់ទៅនៅស្វាយចេក ទៅនៅស្វាយចេកទៅបានបែកការណ៍ ទៅបង្កើតជារឿងបាន ។

ប៊ុនថនៈ បាទ ។

ជួនៈ គេហៅទៅបាត់ខ្ញុំឈប់ជួបគាត់តាំងពីកាលនោះមក ។

ប៊ុនថនៈ តែគាត់មកដល់ដំបូងជាមួយអ្នកភូមិអីយ៉ាងម៉េចដែលគាត់?

ជួនៈ ខ្ញុំក្តាប់មិនបានត្រង់ស្អីៗខ្ញុំស្តាប់មិនបាន គាត់មករកស៊ីធម្មតាទៅខ្ញុំនៅឆ្ងាយដែលខ្ញុំនៅ កណ្តាលភូមិនោះខ្ញុំមិនដែលបានមករកស៊ីគ្រាន់តែយូរៗមកលេងម្តងណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ឃើញយើងចេះនិយាយលេងនិយាយសើចទៅចេះតែនិយមទំនាក់ទំនងគ្នាទៅ ដឹងចិត្តគាត់ ឃើញគាត់មកនៅចឹងឃើញគាត់រក្សាចិត្តគំនិតសីលធម៌របស់គាត់ តា ខុចមែនហើយបើ និយាយរឿងអីច្បាស់របស់គាត់មែន គាត់ធ្វើចិត្តសាស្ត្ររបស់គាត់ល្អណាស់ គាត់ធ្វើមានពី ណាចាប់អារម្មណ៍គាត់ថា គាត់ជាមេគុកទេកាលហ្នឹង ។

ប៊ុនថនៈ បាទ!អ្នកភូមិអីរាប់អានគាត់ធម្មតា?

ជួនៈ បាទ!ធម្មតាគាត់នៅនេះគាត់អត់មានធ្វើអីឲ្យពីណាខឹងទេ អត់មានទេ គាត់បំរ៉ុងចង់ជាជន្លង អីទៀត តែទីបញ្ចប់អត់មានបាន ។

ប៊ុនថនៈ ចង់ឲ្យកូនគាត់មានគ្រួសារ?

ជួនៈ បាទៗ!កូនស្រីគាត់ម៉ឺមួយចង់បានកូនអ្នកស្រុកនេះដល់គាត់មានរឿងចេះទៅផុតទៅ ។

ប៊ុនថនៈ កូនគាត់មានប៉ុន្មាននាក់ពូ?

ជួនៈ កូនគាត់កាលនោះមានពីឬមួយទេ ដូចជាប្អូននាក់ស្រីមួយម៉ីបងម៉ីនោះហើយដែលចង់ឲ្យបានប្តីនៅនេះ ។

ប៊ុនថនៈ កាលនៅជិតគ្នាពូខស្បាហ៍ជំនុំជាមួយគាត់ដែរ?

ជួនៈ ចុះដីស្រែខ្ញុំនៅនេះខ្ញុំខស្បាហ៍មក តែមកដល់គាត់ គាត់ហៅខ្ញុំចូលលេងហើយ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំដើរមកគាត់ហៅថា ជួនចូលលេងជជែកគ្នាលេងទៅ ខ្ញុំសួរពីការរកស៊ីចេះចុះទៅ គាត់មានម៉ាស៊ីនស្រូវគាត់មានអីណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ជជែកសិក្សាតែរឿងចុះឯង ។

ប៊ុនថនៈ គាត់មិនដែលនិយាយរឿងប្រទេសជាតិអីទេ?

ជួនៈ គាត់មិនដែលនិយាយទេ គាត់មិនដែលនិយាយសោះ មិនដែលនិយាយរឿងពីដើមមិញខ្ញុំធ្លាប់ដឹកនាំគេចេះចុះៗមិនដែលទេ ។

ប៊ុនថនៈ លាក់ឡើងជិត?

ជួនៈ លាក់ឡើងជិតខ្ញុំមិនដែលដឹងសោះ ដល់ពេលទៅនោះគេថា តា ឌុចៗពុឈ្មោះ តា ឌុចៗ គេថា តា ពិនទៅពីផ្កាំទៅ ខ្ញុំមិនដែលដឹងរឿងអី ។

ប៊ុនថនៈ ដឹងពីពេលណា?

ជួនៈ ទើបដឹងដែលគេយកទៅហើយ បើសិនដឹងរឿងកាលនោះឯងខ្ញុំសួរទាំងអស់ខ្ញុំធ្លាប់គេធ្វើបាបខ្ញុំដែលនោះ ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំមិនដែលដឹងបើខ្ញុំគេឆក់ខ្មែរក្រហម ខ្ញុំគេអ៊ុតសំពត់ភ្លៀងបើគេឲ្យធ្វើចុះខ្ញុំសួរដឹងអស់ហើយ ។

ប៊ុនថនៈ បាទ!ចឹងកាលពូនៅហ្នឹងពូមានដឹងថា តា ញឹមអីគេចាប់ដែរ?

ជួនៈ តា ញឹមខ្ញុំដឹងថា តាំងពីកាលខ្ញុំជាប់នោះគេថាចាប់តា ញឹមតាអីយកទៅសម្លាប់ចោលអី ។

ប៊ុនថនៈ ចុះអនុគាត់ថាជូនពូទៅកកោះនោះ?

ជួនៈ ភ្លេចឈ្មោះ ឈ្មោះអីទេ ភ្លេចឈ្មោះហើយ កាលនោះគាត់មិនទាន់ស្លាប់ទេ ខ្ញុំតាំងពីគេឆក់ខ្មែរក្រហមមកខួរក្បាលដូចជាមិនសូវនេះទេ ។

ប៊ុនថនៈ តែគាត់គេចាប់ដែលឬមួយអត់ទេ?

ជួនៈ កាលនោះមិនទាន់ចាប់ទេ កាលខ្ញុំទៅជាប់គុកហើយណាស់ ។

ប៊ុនថន: បាទ ។

ជួន: មិនទាន់ចាប់ទេ នៅតែគាត់មួយនិងឯង ។

ប៊ុនថន: ចឹងនៅពេលខាងនិរតីមកអីពូមានដឹងទេ?

ជួន: និរតីមកខ្ញុំទៅជាប់គុកកកោះហើយបាននិរតីមកហ្នឹង ខ្ញុំបាននិយាយបានគុណបុណ្យដល់ទីបញ្ចប់គេខាងនិរតីនៅជុំខ្ញុំអត់មាននិរតីទេ ពួកយើងអ្នកពោធិសាត់ខ្ញុំបានប្រពន្ធអ្នកពោធិសាត់ ។

ប៊ុនថន: បាទ ។

ជួន: អ្នកពោធិសាត់កំពង់ឆ្នាំង ។

ប៊ុនថន: បាទ ។

ជួន: ហៅគ្នានិរតីកាលនោះ ហៅពួកនិរតី ។

ប៊ុនថន: បាទ ។

ជួន: ពួកនោះមកមានអីខ្ញុំបានរស់រានមានជីវិត ខ្ញុំទៅនៅគេខ្ញុំរៀននិយាយតាមភាសាគេ គេមិនជឿខ្ញុំថាអ្នកពាយ័ព្យណា ។

ប៊ុនថន: បាទ ។

ជួន: ខ្លះគេថាខ្ញុំចំអកឲ្យគេ ។

ប៊ុនថន: បាទ ។

ជួន: ខ្ញុំពាយ័ព្យថាខ្ញុំចំអកឲ្យគេ ។

ប៊ុនថន: ចឹងចង់សួរពូបកទៅក្រោយបន្តិច?

ជួន: បាទ ។

ប៊ុនថន: ចង់សួរពីកាលពីពូចេញពីលន់ នល់មកភូមិនេះ ពូនៅភូមិបានប៉ុន្មានបានគេរំដោះបានណាស់?

ជួន: ខ្ញុំមកពីហ្នឹងមកគិតមើល៨១-៨២-៨៣និយាយរួមទៅនៅអត់បាន ។

ប៊ុនថន: អត់ទេ និយាយកាល៧០ជាង?

ជួន: ៧៣-៧៤នៅបានពីរឆ្នាំប៉ុណ្ណោះឯង ។

ប៊ុនថន: មកនៅភូមិបានពីរឆ្នាំ?

ជួន: បាទ! ៧៤-៧៥គេរំដោះគេវៃបាត់ហើយ ។

ប៊ុនថន: បាទ ។

ជួនៈ ៧៨ខ្មែរក្រហមមកពេញនេះអស់ហើយ ។

ប៊ុនថនៈ ខ្មែរក្រហមចូលមកនៅឆ្នាំណា?

ជួនៈ ៧៨តាមព្រៃស្មុទ្ធតែខ្មែរក្រហមនៅតែវៃមិនទាន់បាន វៃបានវៃបាន៧៨ហ្នឹងហើយចុងឆ្នាំ ។

ប៊ុនថនៈ ចឹងទិប្រជុំជនអីមិនទាន់ចូលមកដល់ទេ?

ជួនៈ មិនទាន់ចូលមកដល់ទេ វៃនេះបែកអស់បញ្ជូនអ្នកស្រុកឲ្យទៅនៅសៀមរាប ។

ប៊ុនថនៈ ចឹងកាលពូចូលដំបូងចូលទៅកងវរៈអីប៉ុន្មានពូ?

ជួនៈ កាលហ្នឹងនៅ៤១៥ ។

ប៊ុនថនៈ ៤១៥?

ជួនៈ បាទ!៤១៥វរៈ៤១៥មេខ្ញុំឈ្មោះ លាងទៅជាប់គុកដូចតែគ្នាហ្នឹង ។

ប៊ុនថនៈ គេចាប់ទៅដែរ?

ជួនៈ ជាប់គុកទៅមិនដឹងជាណា ស្លាប់អស់ ។

ប៊ុនថនៈ ចឹង៤១៥ហ្នឹងកងពលលេខប៉ុន្មានពូ?

ជួនៈ កាលនោះគេហៅតំបន់ ។

ប៊ុនថនៈ គេហៅតំបន់?

ជួនៈ បាទ!តំបន់៥ ។

ប៊ុនថនៈ ពីណាជាប្រធានតំបន់?

ជួនៈ ប្រធានតំបន់កាលនោះ តា ធនប្រធានតំបន់មិនស្គាល់ផងកាលនោះ ។

ប៊ុនថនៈ តំបន់៥មានស្រុកអីខ្លះពូ?

ជួនៈ តំបន់៥និយាយរួចទៅម៉ាជិនារថ្នល់ខាងនេះ ម៉ាជិនារថ្នល់ខាងនេះតំបន់៥ ម៉ាជិនារថ្នល់ខាងនោះតំបន់៤ ភ្នំស្រុក ថ្មពួក ទៅចេះគេហៅតំបន់៥ បើខាងក្រោយថ្នល់លេខ៦នេះតំបន់៤ហើយ ។

ប៊ុនថនៈ បាទ!ចឹងពូចូលហើយហ្នឹងបានពូទៅប៉ោយប៉ែតហ្នឹង?

ជួនៈ បាទ!ចូលហើយបានគេយកទៅរៀបចំភូមិភាគកាលហ្នឹង គេយកខ្ញុំពី៤១៥ទៅ ទៅនៅភូមិភាគកាលហ្នឹង ភូមិភាគ២២៧ ។

ប៊ុនថនៈ ភូមិភាគ២២៧?

ជួនៈ បាទ!កន្លែងវរៈ២២៧ ។

ប៊ុនថនៈ បាទ ។

ជួនៈ បានគេចាប់ខ្ញុំពី២២៧/បានមកកន្លែងកសាងខ្លួនរហូតដល់វៀតណាមចូល ។

ប៊ុនថនៈ ចឹងមេៗអីពូដែលធ្លាប់ជួបដែរ ដូចជាមេភូមិភាគមេតំបន់អី?

ជួនៈ បានជួបប្រជុំម្ដងៗ ។

ប៊ុនថនៈ តែពូមិនសូវបានដឹងរឿងអីទេ?

ជួនៈ ខ្ញុំមិនដែលបានដឹងរឿងទេ ខ្ញុំឆ្ងល់មិនដែលបានដឹងរឿង ខ្ញុំឆ្ងល់ចេះខ្ញុំទៅនៅប៉ោយប៉ែតខ្ញុំហើយការពារពាណិជ្ជកម្មទិញឥវ៉ាន់ទិញអង្ករអំបិលទិញកង់ឡានបញ្ជូនយកមកឲ្យប្រជាពលរដ្ឋតែទីបញ្ចប់ម៉េចបានប្រជាពលរដ្ឋអត់ឃ្លាន ។

ប៊ុនថនៈ ចឹងពូនៅនោះខាងពាណិជ្ជកម្មទេ?

ជួនៈ ខ្ញុំនៅកងទ័ពតែការពារពាណិជ្ជកម្ម ។

ប៊ុនថនៈ បាទ ។

ជួនៈ គា គង់ៗប្រាក់ទាំងប៉ាវដុល្លាទាំងប៉ាវទិញប្រេងទិញអំបិលទិញអង្ករពីថៃមកណាស់ ការពារមានចោរថៃប្លន់ពាណិជ្ជកម្មទៀត ប្លន់ចាក់ឡើងយកលុយបាន តែយកលុយមិនបានច្រើនទេ ចងក្របួចកប៉ិ ង៉ុន ចងកន្សែងកចេះ ចងបានបុកនិងកាំបិតប្លន់យកបានប្រាក់ទៅ ឯងបានម៉ារបួស ។

ប៊ុនថនៈ បាទ ។

ជួនៈ ខ្ញុំដល់ពេលបើលុយឲ្យថៃម្ដងថ្ងៃទិញអីៗខ្ញុំការពារលុយហ្នឹង ។

ប៊ុនថនៈ បាទ ។

ជួនៈ នៅយាមឲ្យគេលុយទាំងប៉ាវ លុយទាំងបាវឆ្នូតមិនធម្មតាទិញ ។

ប៊ុនថនៈ រាប់យ៉ាងម៉េចទៅ?

ជួនៈ ទិញចេះតែកត់ចូលទៅមានចៅកែមួយៗមានចៅកែគេណាស់ ប្រេងទិញមកមួយអាទិត្យបើកម្ដងលុយទាំងបាវ ។

ប៊ុនថនៈ កាលពូនៅអូរជ្រៅហ្នឹង?

ជួនៈ បាទ!ខ្ញុំការពារខ្ញុំអង្គុយយាមគេហ្នឹង ពាណិជ្ជកម្មគេរាប់ប្រាក់ឲ្យគេហៅឈ្មោះ «ក» ។

ប៊ុនថនៈ បាទ ។

ជួនៈ លុយប៉ុន្មាន ត្រូវបើកប៉ុន្មានបញ្ជីរគេមានណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ យកកន្ទុយសែកមក មកដល់រាប់ប្រាក់ឲ្យព្រះចេញទៅ ដល់ហើយ«ខ» គិតលុយតាម«ខ» ថ្ងៃអីចឹងទៅ«ក-ខ-គ-ឃ-ងចឹងទៅ» ។

ប៊ុនថនៈ បាទ!តែយើងនេះយ៉ាងម៉េចបើជំនាន់ហ្នឹងយើងអត់មានចាយលុយណា?

ជួនៈ អត់ទេ ខ្ញុំការពារទាំងអ្នកលក់ត្បូងពេជ្រទៀតនេះ ប៉ុននេះពេជ្របើខ្ញុំគិតឃើញបើខ្ញុំនាំកុងសែនោះរត់វិញ តែបើរត់ទៅក៏មិនរស់ដែរ ទៅស្រុកថៃហ្នឹង ថៃមិនដែលមានលុយទិញទេ ប៉ុនៗនេះ ប៉ុនៗម្រាមដៃ ។

ប៊ុនថនៈ បាទ ។

ជួនៈ កុងសែតា នោះគាត់មិនដឹងឈ្មោះអីទេ គាត់នៅប៉ៃលិនគេយកគាត់មកឲ្យកាន់ខាងត្បូងលក់ឲ្យពាណិជ្ជកម្ម ។

ប៊ុនថនៈ បាទ ។

ជួនៈ ថៃមកឃើញផ្អើលអស់ ខ្ញុំកាំភ្លើងមួយដើមការពារគាត់ជញ្ជីងមួយកាន់ជញ្ជីងមួយ គាត់ដើរលីអាថង់ប៉ុននេះ បើសិនជាមានមនុស្សរត់គេ គេរត់ទៅថៃម៉ាកគោគដីណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ យើងអត់មានគំនិតអីរត់ទេ បើសិនជានាំបបួលបងឯងរត់ចូលថៃ មានធ្វើអាចម៍អីយើងខុបឃិតឲ្យថៃពាក់កណ្ដាលយើងពាក់កណ្ដាលទៅធ្វើមហាសេដ្ឋីទៅបាន ថៃមកឃើញអត់មានលុយទិញទេ ខ្ញុំប្រាប់ច្រើនណាស់ ។

ប៊ុនថនៈ មានរបស់របរច្រើន?

ជួនៈ វាមិនមានលុយទិញផ្ទះមួយស្វាត់ចេះខ្ញុំអ្នកការពារ ។

ប៊ុនថនៈ ចឹងរបស់លក់បានយកឲ្យខ្មែរក្រហមវិញ?

ជួនៈ លក់បានលុយទៅប្រគល់ឲ្យប្រធានគេ បង្វិលទិញកង់ឡានទិញកង់អាត្រាក់អីណាស់ ។

ប៊ុនថនៈ បាទ ។

ជួនៈ ទិញអំបិលទិញស្ករទិញអីមកពីថៃវិញ តែយើងអត់មានសិទ្ធចាយអីទេ ហូបតែបាយដាំបាយលាយត្រកួនឲ្យស៊ីហ្នឹង ។

ប៊ុនថនៈ ចឹងលុយហ្នឹងបានមកពីណា លុយដុល្លាអី?

ជួនៈ ដឹងគេដឹកពីភ្នំពេញ ចេញពីភ្នំពេញមក ។

ប៊ុនថនៈ បាទ ។

ជួនៈ ពាណិជ្ជកម្មទូទាំងប្រទេសមកពីនោះគេដឹកមកគេហៅទៅប្រជុំតាមភូមិភាគ ភូមិភាគគេដឹកមកលុយទាំងបាវ ។

ប៊ុនថនៈ តែមានលុយខ្មែរទេ?

ជួនៈ អត់មានទេ មានតែដុល្លាសុទ្ធ ។

ប៊ុនថនៈ ចឹងក្រៅពីដុល្លាមានលុយអីផ្សេងទេ?

ជួនៈ អត់មាន មានតែដុល្លា លុយបាតទៅតាមនោះបើយើងយក យើងអត់មានសិទ្ធចាយផង ។

ប៊ុនថនៈ ចឹងកាលហ្នឹងពូមានដឹងថាគេអត់ចាយលុយនៅ?

ជួនៈ ដឹងតើយើងមានពិបាកចាយលុយអីមេទិញឲ្យទិញតាមលុយតាមសេដ្ឋកិច្ចគេមានពិបាកអីត្រូវចាយទេ ។

ប៊ុនថនៈ បាទ ។

ជួនៈ គ្រាន់តែមាសខ្សែក គេអ្នកហ៊ានយក គេយកទៅធ្វើខ្សែចង្កៀងខ្សែអីខ្ញុំមិនដែលហ៊ានយកមិនដែលស្គាល់ជាតិ ។

ប៊ុនថនៈ បាទ ។

ជួនៈ សាប៊ូណាស់មានពីរដុំគេដកមួយដុំហើយពួកខ្ញុំ គេឲ្យមានតែមួយដុំទេ ។

ប៊ុនថនៈ បាទ ។

ជួនៈ សាប៊ូពេញប៉ោយប៉ែត ចុះក្នុងផ្សារដែលខូះសាប៊ូ គេឆែកមើលសាក់កាដូយើងឲ្យតែឃើញពីរដុំគេដកមួយដុំហើយមេ ។

ប៊ុនថនៈ បាទ ។

ជួនៈ គេមេកងធំ ប្រាសដុះធ្មេញមានពីរដកមួយឲ្យប្រើអស់បានឲ្យមួយទៀត ។

ប៊ុនថនៈ បាទ ។

ជួនៈ ឲ្យយកមួយទៀតអារបស់មិនពិបាកបែកសោះ អារបស់នៅក្នុងផ្ទះចោលសោះហ្នឹង ។

ប៊ុនថនៈ បាទ!ចឹងឆ្លងទៅវិញទៅមកនៅថៃបានទេពូ?

ជួនៈ អត់ឲ្យទេ ។

ប៊ុនថនៈ មានទាហានអីនៅហ្នឹងពូ?

ជួនៈ មានមកទាក់ទងពួកខ្ញុំនិងត្រឹមស្ពានទេ ។

ប៊ុនថនៈ ស្ពានរាល់ថ្ងៃហ្នឹង?

ជួនៈ បាទ!កាលនោះស្ពានតូច ។

ប៊ុនថន៖ បាទ ។

ជួន៖ ហ្នឹងស្ពានមកចេះបើសក្តិ៥មានមកចេះ មកចេះមានបោយគេណាស់ ស្រុកគេចូលចិត្តហៅបោយណាស់ ។

ប៊ុនថន៖ បាទ ។

ជួន៖ សព្វថ្ងៃគេហៅអន្ទរក្សណាស់ ។

ប៊ុនថន៖ បាទ ។

ជួន៖ កាលហ្នឹងគេហៅបោយ គេយកមកខ្ញុំចង់ដឹងគេយកមកជួបយើងចេះមេមកជួបខ្ញុំចេះ កាលហ្នឹងខ្ញុំមិនមានធ្វើអីគ្រាន់តែយាម ។

ប៊ុនថន៖ បាទ ។

ជួន៖ គេមកសុំជួបទំនាក់ទំនងចេះ មេខ្មែរក្រហមមិនឲ្យជួប គេមកជួបមកដល់ចាប់ដៃយើង ដៃគេឡើងក្រហម គេយកសាវម៉ាវមកមួយការ៉ុងចេះមកដល់ឲ្យយើង មានបានស៊ីទេ មេយើងយកទៅបាត់ទម្លាក់ទឹកស្ពានវិញក្តួង ។

ប៊ុនថន៖ យ៉ាងម៉េចចឹង?

ជួន៖ គេមិនឲ្យយើងស៊ីទេ ខ្លាចយើងឈ្លក់និងនយោបាយគេ ដឹងហើយសម័យខ្មែរក្រហមមិនដែលបានស៊ី បើស៊ីលួចស៊ីតែស៊ីមិនស្រួល ៗ ថាយើងចូលបក្សសម្ព័ន្ធណាណី ។

ប៊ុនថន៖ បាទ ។

ជួន៖ គ្នាលីសាវម៉ាវទាំងការ៉ុងយកមកឲ្យហើយយកកាំបិតឆូតចោលទម្លាក់ក្នុងទឹក ។

ប៊ុនថន៖ តែឆូតនៅមុខហ្នឹងតែម្តង?

ជួន៖ ទេ គេទៅផុតឆូតចោលទៅអត់ឲ្យយើងស៊ីខ្លាចយើងចូលបក្សសម្ព័ន្ធអីណា ។

ប៊ុនថន៖ បាទ ។

ជួន៖ សាហាវណាស់ គិតទៅធ្វើផ្តាច់ការតែម្តង ។

ប៊ុនថន៖ បាទ ។

ជួន៖ ខ្ញុំថាយើងរស់នៅកាលនោះខ្លាចអំណាចគេដែរ ធ្វើតែអំពើល្អមិនដែលបានល្អខ្ញុំ ។

ប៊ុនថន៖ បាទ ។

ជួន៖ មិនដែលបានល្អទេ មិនត្រូវខ្ញុំថាទេ ទោះបីខ្ញុំខំសម្អាតផ្ទះមានពីណាយកដេះទៅដាក់ហ្នឹង ។

ប៊ុនថន៖ បាទ ។

ជួន៖ ធុងទឹកក្តោងឯងឡើងចាស់ ប្រឡាក់ឡើងប្រលុះ ។

ប៊ុនថន: បាទ ។

ជួន: ចោទថាឯងមិនចេះសម្អាតមិនចេះអី ទីបញ្ចប់ងាប់អស់រលីង ។

ប៊ុនថន: បាទ ។

ជួន: ពួកខូច ។

ប៊ុនថន: ចឹងរាល់ថ្ងៃនេះពូមានកូនប៉ុន្មាននាក់ពូ?

ជួន: កូនខ្ញុំមានបួននាក់ ៥នាក់ស្លាប់មួយ ។

ប៊ុនថន: បាទ ។

ជួន: កូនបែកបាក់អស់ហើយខ្លះមានប្តីទៅរកស៊ីថៃ ។

ប៊ុនថន: បាទ ។

ជួន: អាមួយឈឺកើតស្កន់តាំងពិតូចមកអាយុ១៩ឆ្នាំស្លាប់ នៅមួយនៅរៀនបានមួយបានប្តីនោះ ។

ប៊ុនថន: បាទ ។

ជួន: កូនបងប្អូនជីដូនមួយនៅអាមេរិច បានមួយទៅអាមេរិច ។

ប៊ុនថន: បាទ!ទៅអាមេរិច ។

ជួន: បាទ ។

ប៊ុនថន: ចឹងពូរកអីរាល់ថ្ងៃ?

ជួន: ខ្ញុំមានរកអីទេ បានធ្វើស្រែបន្តិចៗហ្នឹងខ្ញុំបានយាមសេវានេះផង ខ្ញុំពង្រីកមុខរបរនេះលាងឡានទៅ លាងថ្ងៃណាបានក៏លាងបើខែវស្សាបានខ្លះ ។

ប៊ុនថន: បាទ ។

ជួន: គិតក់ថារកម៉ាស៊ីនបោកស្រូវមើលថាឲ្យកូនមកបានពិបាកតែខ្លួនឯងនេះអត់មានបានអីបានម៉ាស៊ីនចាស់ផងទៅ ។

ប៊ុនថន: បាទ ។

ជួន: ធ្វើកម្មខ្លួនឯងរកចំណូលមិនបានទេប្អូនអើយ ។

ប៊ុនថន: ចឹងភូមិនេះភូមិអីវិញពូ?

ជួន: ភូមិផ្គាំ ។

ប៊ុនថន: ភូមិផ្គាំ?

ជួន: ភូមិផ្គាំ ឃុំផ្គាំ ។

ប៊ុនថន៖ ខ្ញុំដូចជាអស់អីសួរពូទៀតហើយ ។

ជួន៖ ដឹងចង់សួរអីទៀតផង ។

ប៊ុនថន៖ បាទ! ខ្ញុំដូចជាអស់អីសួរហើយខ្ញុំអរគុណច្រើន ។

ជួន៖ បាទ ។

**ចប់**